# យុទ្ធសាស្ត្រគ្រប់គ្រងតំបន់ដីមោកក្នុងប្រទេសអាស៊ាន



Global Environment Centre

# យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងតំបន់ដីមោកប្រកប ដោយនិរន្តរភាព ក្នុងប្រទេសអាស៊ាន

## ក្រោមក្របខ័ណ្ឌ នៃគំនិតផ្តួចផ្តើមការគ្រប់គ្រងតំបន់ដីមោអាស៊ាន (AMPI)

អនុម័ត ក្នុងកិច្ចប្រជុំលើកទី ១២ នៃក្រុមការងារបច្ចេកទេសផ្សែងអ័ព្ទ ASOEN (HTTF) ចាប់ពីថ្ងៃទី១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ នៅទីក្រុងបាន់ដាសេរីបេហ្គាវ៉ាន់ ប្រទេសប្រុយណេដារ៉ូសាឡឹម និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីបរិស្ថានលើកទី១០ (AMME) នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ។

រៀបចំដោយលេខាធិការដ្ឋានអាស៊ាន ដោយមានការគាំទ្រពីមជ្ឈមណ្ឌលបរិស្ថានពិភពលោក ( GEC) និងមានការប្រឹក្សាយោបល់យ៉ាងជិតដល់ជាមួយបណ្តាប្រទេសអាស៊ាន

រៀបចំបកប្រែដោយនាយកដ្ឋានតំបន់ដីសើម និងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន

ឧបត្ថម្ភការបោះពុម្ពជាភាសាខ្មែរដោយ:

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានបង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧។ ប្រទេសសមាជិកសមាគមនេះ រួមមានប្រទេសប្រ៊ុយណេដារូសាឡឹម ប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី ប្រទេសឡាវ ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន ប្រទេសសិង្ហបុរី ប្រទេសថៃ និងប្រទេសវៀតណាម។ លេខាធិការអាស៊ានមានទីតាំងស្ថិតនៅក្នុងទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

**ការិយាល័យកិច្ចការសាធារណៈ នៃលេខាធិការអាស៊ាន**

70A Jalan Sisingamangaraja ទីក្រុងហ្សាកាតា១២១១០ ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ: (៦២ ២១) ៧២៤ ៣៣៧២, ៧២៦ ២៩៩១
ទូរសារ: (៦២ ២១) ៧៣៩ ៨២៣៤, ៧២៤ ៣៥០៤
សារអេឡិកត្រូនិក: public@aseansec.org
ព័ត៌មានទូទៅ ស្តីពីអាស៊ានអាចមើលលើ គេហ៍ទំព័រអាស៊ាន www.aseansec.org

កាតាឡុក ក្នុងទិន្នន័យសម្រាប់ការផ្សព្វផ្សាយ

**យុទ្ធសាស្ត្រគ្រប់គ្រងតំបន់ដីមមោកក្នុងប្រទេសអាស៊ាន**

iii, ទំព័រ ២៥, ១៦ សង់ទីម៉ែត្រ

១. ការគ្រប់គ្រងតំបន់ដីមមោក-អាស៊ាន
២. ការគ្រប់គ្រងតំបន់ដីមមោក-អាស៊ី, ភាគអាគ្នេយ៍
៣. ការគ្រប់គ្រងបរិស្ថាន-អាស៊ាន

៣៣៣.៧៣៥៩

លេខឯកសារ ៩៧៨៩៧៩៣៤៩៦៤២៩

ឯកសារនេះអាចធ្វើការដកស្រង់ ឬបោះពុម្ពឡើងវិញបាន ប្រសិនបើមានការទទួលស្គាល់កម្មសិទ្ធិត្រឹមត្រូវ។

កម្មសិទ្ធិរបស់លេខាធិការអាស៊ានឆ្នាំ២០០៧រាល់កម្មសិទ្ធិទាំងអស់មានការការពារ
ឯកសារនេះបោះពុម្ពលើកទី ១ ក្នុងឆ្នាំ ២០១១ ក្នុងប្រទេសកម្ពុជា

# តារាងមាតិកា


អារម្ភកថា ..................................................................... 1

**1 សេចក្តីផ្តើមនៃតំបន់ដីមមោកក្នុងតំបន់អាស៊ាន** ..................................... 5

1.1 របាយតំបន់ដីមមោកក្នុងប្រទេសអាស៊ាន ..................................... 5

1.2 វិសាលភាព នៃតំបន់មមោក ..................................... 6

1.3 ការប្រើប្រាស់ និងអត្ថប្រយោជន៍ នៃតំបន់ដីមមោកក្នុងអាស៊ាន..... 6

1.4 គោលនយោបាយ និងក្របខ័ណ្ឌស្ថាប័ន ពាក់ព័ន្ធនឹងតំបន់ដីមមោក ..................................... 6

1.5 បញ្ហា និងការព្រួយបារម្ភទូទៅ ..................................... 7

1.6 តម្រូវការទូទៅពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក ..................................... 11

1.7 សហប្រតិបត្តិការក្នុងតំបន់ ..................................... 12

**2 យុទ្ធសាស្រ្តថ្នាក់តំបន់ សម្រាប់ការគ្រប់គ្រងតំបន់ដីមមោក** ..................................... 18

2.1 សារតារបស់យុទ្ធសាស្រ្ត ..................................... 18

2.2 បញ្ហាប្រឈម សម្រាប់ការអភិរក្ស និងគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព ..................................... 18

2.3 សនិទានភាព សម្រាប់យុទ្ធសាស្រ្តថ្នាក់តំបន់ ..................................... 19

2.4 គោលដៅ ..................................... 21

2.5 គោលបំណងទូទៅ ..................................... 22

2.6 ផែនការសកម្មភាព ..................................... 23

2.7 ផែនការសកម្មភាពថ្នាក់ជាតិ (NAPs) ..................................... 28

3 **យន្តការអនុវត្តន៍**......................................................................73

3.1 យន្តការអនុវត្តថ្នាក់តំបន់ ..................................................................73

3.2 យន្តការអនុវត្តថ្នាក់ប្រទេស .................................................................76

3.3 ការប្រើប្រាស់ធនធាន ..........................................................................79

3.4 យន្តការតាមដាន និងវាយតម្លៃ ..........................................................80

## បញ្ជីតារាង

តារាង ១ តារាងបង្ហាញពីវិស័យស្នូល និងគោលបំណងអនុវត្ត .....១៦

តារាង ២ ផែនការសកម្មភាពយុទ្ធសាស្ត្រ សម្រាប់ការគ្រប់គ្រងតំបន់ដីមមោកអាស៊ាន (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៥) .........២០

## បញ្ជី នៃដ្យាក្រាម

ដ្យាក្រាម ១ តារាងលំហូរបង្ហាញអំពីរចនាសម្ព័ន្ធ នៃគំនិតផ្តួចផ្តើម ការគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព ( APMI) ដែលរៀបរៀងឡើង ក្នុងគោលបំណងធ្វើជាមគ្គុទ្ទេសន៍ និងការអនុវត្តឲបានស៊ីសង្វាក់គ្នានឹងការអនុវត្តយុទ្ធសាស្ត្រថ្នាក់តំបន់..........................................................................៤២

ដ្យាក្រាម ២ តារាងលំហូរបង្ហាញអំពីយន្តការ ដែលបានស្នើឡើងសម្រាប់អនុវត្តយុទ្ធសាស្ត្រនៅថ្នាក់ជាតិ......................៤៥

## អារម្ភកថា

ការរៀបចំនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព ក្នុងប្រទេសអាស៊ាន (ឬហៅកាត់ថា យុទ្ធសាស្ត្រគ្រប់គ្រងតំបន់ដីមមោកក្នុងប្រទេសអាស៊ាន APMS) បានរៀបរៀងឡើងដោយប្រទេសសមាជិកអាស៊ាន ដើម្បីធ្វើជាឯកសារមគ្គុទ្ទេសន៍នៃសកម្មភាពការងារ ដែលគាំទ្រដល់ការគ្រប់គ្រងតំបន់ដីមមោ ក នៅក្នុងតំបន់ចាប់ពី២០០៦ ដល់ ឆ្នាំ២០២០។ APMS ត្រូវបានរៀបរៀងឡើងដោយសារមានតម្រូវការជាចាំបាច់ ដែលទទួលស្គាល់ដោយសហាគមន៍មូលដ្ឋាន និងសហាគមន៍អន្តរជាតិ ចំពោះការប្រើប្រាស់ដោយឈ្លាសវៃ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោ ក ជាពិសេស ការគម្រាមកំហែងបង្កដោយអគ្គីភ័យ និងផ្សែងអ័ព្ទ ក្នុងតំបន់ដីមមោ ក ចំពោះសេដ្ឋកិច្ច និងសុខភាពនៅក្នុងតំបន់ រួមនឹងភាពអាចកើតមានឡើងនៃការចូលរួមចំណែករបស់អគ្គីភ័យ ក្នុងតំបន់ដីមមោ ក ដល់ ការប្រែប្រួលអាកាសធាតុ។ APMS ត្រូវបានបង្កើតឡើងក្រោមក្របខ័ណ្ឌគំនិតផ្តួចផ្តើមការគ្រប់គ្រងតំបន់ដីមមោកក្នុងប្រទេសអាស៊ាន ( APMI) និងកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន។

APMI បានស្នើឡើងដំបូង ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីអំពីផ្សែងអ័ព្ទ (AMMH) នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០២ ក្នុងទីក្រុងកូឡាឡាំពួ រ ប្រទេសម៉ាឡេស៊ី ហើយត្រូវបានអនុម័ត ក្នុងកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន លើកទី២០ ស្តីពីក្រុមការងារបច្ចេកទេសបរិស្ថាន -ផ្សែងអ័ព្ទ ( ASOEN-HTTF) នៅទីក្រុងម៉ានីឡា នាខែកុម្ភៈ ឆ្នាំ២០០៣ រួមជាមួយនឹងផែនការការងារដំបូង (២០០៣-២០០៥)។ ឯកសារនេះត្រូវបានលើកយកមកពិភាក្សាម្តងទៀត

នៅកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានលើកទី១០ នៅទីក្រុងសៀមរាប ប្រទេសកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៣។

ផែនការការងារដំបូង (២០០២ -២០០៥) របស់ APMI គឺ ធ្វើការរៀបរៀងឡើង នូវយុទ្ធសាស្ត្រថ្នាក់តំបន់ តាមរយៈការ ស្នើសុំឲ្យប្រទេសសមាជិកអាស៊ាននីមួយៗផ្តល់នូវព័ត៌មានមូលដ្ឋាន និងឯកសារថ្នាក់ជាតិ ។ បន្ទាប់មកធ្វើការបង្ហាញឯកសារទាំងនោះ ជូនដល់សិក្ខាសាលាថ្នាក់តំបន់លើកទី១ ដែលប្រារព្ធឡើងកាលពីខែតុលា ឆ្នាំ២០០៣ នៅទីក្រុងបូហ្គោ ប្រទេសឥណ្ឌូនេស៊ី។ អង្គសិក្ខាសាលាបានឯកភាពជាឯកច្ឆន្ទ លើគោលគំនិតគ្រោងរបស់យុទ្ធសាស្ត្រ ក៏ដូចជាដំណើរការចាំបាច់ ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រ។ បន្ទាប់មកលេខាធិការដ្ឋានអាស៊ាន ក្រោមជំនួយការរបស់មជ្ឈមណ្ឌលបរិស្ថានពិភពលោក បានធ្វើការអភិវឌ្ឍបន្ថែម លើគោលគំនិតគ្រោង ហើយបានបង្កើតជាយុទ្ធសាស្ត្រមួយមានលក្ខណៈពេញលេញនៅថ្នាក់តំបន់ តាមរយៈការប្រើប្រាស់ នូវលទ្ធផល នៃការពិភាក្សាក្នុងអង្គសិក្ខាសាលាថ្នាក់តំបន់ របាយការណ៍តាមប្រទេស សេចក្តីថ្លែងការណ៍ និងអនុសាសន៍ផ្សេងៗមកពីអង្គសិក្ខាសាលា និងសន្និសីទពាក់ព័ន្ធនឹងតំបន់ដីមោ ក រួមនឹងគោលគំនិត និងយោបល់សំខាន់ៗពីប្រទេសសមាជិកអាស៊ាន ដៃគូ និងអ្នកគាំទ្រ APMI។ សេចក្តីព្រាងលើកទី ១ នៃយុទ្ធសាស្ត្រថ្នាក់តំបន់នេះ ត្រូវបានផ្សព្វផ្សាយដោយលេខាធិការដ្ឋានអាស៊ាន នៅខែកក្កដា ឆ្នាំ២០០៤។ បន្ទាប់មក ក្រុមការងារបានស្នើសុំឲ្យប្រទេសសមាជិកអាស៊ានធ្វើការប្រឹក្សាយោបល់ថ្នាក់ជាតិ ដើម្បីផ្តល់យោបល់លើឯកសារព្រាងនេះ។

ការប្រឹក្សាយោបល់ថ្នាក់ជាតិ លើសេចក្តីព្រាងយុទ្ធសាស្ត្រថ្នាក់តំបន់នេះ បានប្រព្រឹត្តទៅចាប់ពីខែកក្កដា ឆ្នាំ២០០៤ ដល់ ខែឧសភា ឆ្នាំ២០០៥។ ប្រទេសសមាជិកអាស៊ានមួយចំនួន ដូចជាប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសថៃ និងប្រទេសវៀតណាម បានរៀបចំកិច្ចប្រជុំប្រឹក្សា

យោបល់ថ្នាក់ជាតិ។ ចំណែកឯប្រទេសមួយចំនួនទៀតបានផ្តល់ នូវគំនិតយោបល់តាមរយៈការប្រឹក្សាយោបល់ជាមួយនឹងភ្នាក់ងារពាក់ព័ន្ធ។ ក្រោយមក នាខែមិថុនា ឆ្នាំ២០០៥ មានការប្រារព្ធឡើង នូវ សិក្ខាសាលាថ្នាក់តំបន់លើកទី ២ ស្តីអំពី " APMI" ក្នុងទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្នុងគោលបំណងធ្វើការច្របាច់បញ្ចូលគ្នា នូវលទ្ធផល នៃការប្រឹក្សាថ្នាក់ជាតិ និងធ្វើការសម្រេចជាចុងក្រោយ លើឯកសារយុទ្ធសាស្ត្រថ្នាក់តំបន់ព្រាង។ សេចក្តីព្រាងយុទ្ធសាស្ត្រថ្មីនេះ បានបញ្ចូលនូវព័ត៌មានបន្ថែម ដែលបានផ្តល់ដោយប្រទេសសមាជិកអាស៊ាន និ ងយោបល់ពីសិក្ខាសាលាថ្នាក់តំបន់លើកទី ២។

ឯកសារយុទ្ធសាស្ត្រផ្តោតជាសំខាន់ លើគោលបំណងចំបងចំនួនបួនៈ

១. លើកកម្ពស់ការយល់ដឹង និងចំណេះដឹងអំពីតំបន់ដីមោក

២. ធ្វើការដោះស្រាយបញ្ហាការបំពុលផ្សែងអ័ព្ទ និងភាពសឹករេចរឹល នៃបរិស្ថាន

៣. ជំរុញការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមោក

៤. ជំរុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរួមនៅថ្នាក់តំបន់លើបញ្ហាតំបន់ដីមោក

យុទ្ធសាស្ត្រនេះបានដាក់ចេញ នូវគោលបំណងប្រតិបត្តិ ដែលចូលរួមចំណែកដល់ការសម្រេចបាន នូវការងារមួយ ឬច្រើន ក្នុងចំណោមការងារខាងលើ ក៏ដូចជាធ្វើជាឯកសារមគ្គុទ្ទេសន៍ ដល់ប្រទេសសមាជិកអាស៊ាន ស្ថាប័នប្រតិបត្តិនិងដៃគូសហប្រតិបត្តិការផ្សេងៗ តាមរយៈផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាជាក់លាក់ សម្រាប់អនុវត្តសកម្មភាពទាំងអស់នេះ។ ដោយសង្កេតឃើញ នូវតម្រូវការ ក្នុងការបង្កើនបណ្តាញទំនាក់ទំនងពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការដោះស្រាយបញ្ហា

អគ្គីភ័យ និងផ្សែងអ័ព្ទ ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោក និងការកសាងសមត្ថភាពការស្រាវជ្រាវ និងការគ្រប់គ្រង ពាក់ព័ន្ធនឹងតំបន់ដីមមោក យុទ្ធសាស្ត្រនេះអាចដើរតួនាទីចំបង ក្នុងការផ្តល់ នូវកិច្ចសហប្រតិបត្តិការជាផ្លូវការ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន ក្នុងការដោះស្រាយបញ្ហាតំបន់ដីមមោក នៅក្នុងតំបន់។

ប្រទេសជាសមាជិកមានតួនាទី ក្នុងការអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិ ដើម្បីធានាឲ្យបានថាគោលបំណងប្រតិបត្តិ និងគោលបំណងទូទៅអាច សម្រេចទៅបាន។ ការងារនេះអាចសម្រេចបានតាមរយៈការបង្កើតឡើង នូវផែនការសកម្មភាពថ្នាក់ជាតិ ដែលត្រូវធ្វើឡើង តាមរយៈកិច្ចប្រជុំប្រឹក្សា យោបល់ក្នុងចំណោមប្រទេសសមាជិកអាស៊ាន។

# 1 សេចក្តីផ្តើមនៃតំបន់ដីមោកក្នុងតំបន់អាស៊ាន

ខាងក្រោមនេះ គឺជាព័ត៌មានមូលដ្ឋានអំពីតំបន់ដីមោក ក្នុងតំបន់អាស៊ាន។ ព័ត៌មានទាំងនេះភាគច្រើនបានមកពីឯកសារ តាមប្រទេសសមាជិកអាស៊ាន ក្នុងពេលអង្គសិក្ខាសាលាលើកទី១ ស្តីពី APMI ដែលបានប្រព្រឹត្តិទៅនៅក្នុងទីក្រុងបូហ្គោ ប្រទេសឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី១៦-១៧ ខែតុលា ឆ្នាំ ២០០៣ និងឯកសារកែសម្រួលបន្ថែម បានមកពីការ ធ្វើបទបង្ហាញ ក្នុងសិក្ខាសាលាថ្នាក់តំបន់លើកទី ២ ចាប់ពីថ្ងៃទី ២៤-២៦ ខែមិថុនា ឆ្នាំ២០០៥។ ទន្ទឹមនឹងនេះ ព័ត៌មានមួយចំនួនគឺបានមកពីឯកសារផ្លូវការរបស់ APMI និងឯកសារផ្សេងៗទៀត។

## 1.1 របាយតំបន់ដីមោកក្នុងប្រទេសអាស៊ាន

តំបន់ដីមោកក្នុងអាស៊ីអាគ្នេយ៍មានសរុបប្រមាណ ២៥ លានហិកតា ដែលស្មើនឹង ៦០% នៃតំបន់ដីមោ កក្នុងតំបន់ត្រូពិកសរុប ហើយស្មើនឹងប្រមាណ ១០% នៃធនធានតំបន់ដីមោ កទូទាំងពិភពលោក។ មួយភាគធំនៃតំបន់ដីមោកក្នុងអាស៊ីអាគ្នេយ៍ស្ថិតក្នុងប្រទេសឥណ្ឌូនេស៊ី ដែលមានផ្ទៃដីលើសពី ៧០% នៃតំបន់ដីមោ កក្នុងអាស៊ីអាគ្នេយ៍។ តំបន់ដីមោ កសំខាន់ៗផ្សេងទៀត មាននៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសថៃ ប្រទេសវៀតណាម ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម និង ប្រទេសហ្វីលីពីន។ យ៉ាងណាមិញ ការកើនឡើង នូវការអភិវឌ្ឍ ការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លី និងភាពសឹករេចរឹល នៃដី ដែលបង្កឡើងដោយការដុតដី និងការដុតព្រៃ បានធ្វើឲ្យធនធានតំបន់ដីមោកមានការធ្លាក់ចុះយ៉ាងខ្លាំង នាពេល ២ -៣ ឆ្នាំចុងក្រោយនេះ។ តំបន់ដីមោកភាគច្រើន សង្កេតឃើញមាននៅតាមតំបន់វាលទំនាប និងតំបន់ពាក់កណ្តាលឆ្នេរ ដែលមានចំងាយពីតំបន់ទឹកសាបរហូតដល់ ៣០០ គីឡូម៉ែត្រ។ ជម្រៅរបស់តំបន់ដីមោ កអាចមានពី ០.៥ ម៉ែត្រ រហូតដល់លើសពី ១០ ម៉ែត្រ។

## 1.2 វិសាលភាព នៃតំបន់ដីមមោក

ក្នុងប្រទេសជាច្រើន តំបន់ដីមមោ ក ត្រូវបានបង្កើតជាតំបន់អភិរក្ស តំបន់ព្រៃ សម្រាប់ផលិតកម្ម និងដីកសិកម្ម។ ទំហំផ្ទៃដីមានភាពខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត។ ចំណែកឯ ផ្ទៃដីដីមមោកដែលមិនទទួលរងការរំខាន ឬមួយស្ថិតក្នុងភាពល្អឥតខ្ចោះនោះមានទំហំតូចណាស់។

នាពេលបច្ចុប្បន្ននេះ ប្រទេសសមាជិកអាស៊ានភាគច្រើនបានកត់សម្គាល់ នូវតម្រូវការ នៃការប្រើប្រាស់ធនធាន ដែលមានក្នុងតំបន់ដីមមោ ក ប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ ការយកចិត្តទុកដាក់លើតម្លៃអភិរក្ស ក្នុងន័យប្រើប្រាស់ធនធានតំបន់ដីមមោកប្រកបដោយនិរន្តរភាព ត្រូវធ្វើឡើងឲ្យបានខ្លាំងថែមទៀត។ ការ យកចិត្តទុកដាក់លើការងារនេះ នឹងជួយដល់ការគ្រប់គ្រងធនធានឲ្យបានកាន់តែប្រសើរឡើង សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។

## 1.3 ការប្រើប្រាស់ និងអត្ថប្រយោជន៍ នៃតំបន់ដីមមោកក្នុងអាស៊ាន

តំបន់ដីមមោកផ្តល់ នូវអត្ថប្រយោជន៍យ៉ាងច្រើន ដល់ប្រទេសសមា-ជិកអាស៊ានស្ទើរតែទាំងអស់។ អត្ថប្រយោជន៍ និងការប្រើប្រាស់ នៃតំបន់ដីមមោកនៅក្នុងតំបន់ រួមមានការប្រើប្រាស់ សម្រាប់វិស័យកសិកម្ម ព្រៃឈើ ឬលំនៅដ្ឋាន។ អត្ថប្រយោជន៍ និងការប្រើប្រាស់ផ្សេងៗទៀត រួមមានការកាប់ឈើ ការដកហូតអនុផលព្រៃឈើ ការស្តុកទឹក និងផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកជំនន់ ការស្រូបយក និងស្តុកកាបោន ទេសចរណ៍ធម្មជាតិ និងការអភិរក្សជីវចម្រុះ។

## 1.4 គោលនយោបាយ និងក្របខ័ណ្ឌស្ថាប័ន ពាក់ព័ន្ធនឹងតំបន់ដីមមោក

នាពេលបច្ចុប្បន្ន ក្នុងប្រទេសសមាជិកអាស៊ាននៅមិនទាន់មានច្បាប់ ឬគោលនយោបាយជាក់លាក់ណាមួយ ដែលពាក់ព័ន្ធដោយផ្ទាល់ដល់

ការគ្រប់គ្រងតំបន់ដីមមោកឡើយ។ ទិដ្ឋភាព ពផ្សេងៗ នៃការគ្រប់គ្រងតំបន់ដីមមោកគឺមាននៅក្នុងគោលនយោបាយច្បាប់ និងលក្ខន្តិកៈផ្សេងៗ។ ការធ្វើសំយោគគោលនយោបាយ ឬឯកសារច្បាប់ពាក់ព័ន្ធ ឬមួយក៏ធ្វើការបង្កើតនូវគោលនយោបាយ ឬលក្ខន្តិកៈជាក់លាក់ ពាក់ព័ន្ធនឹងតំបន់ដីមមោកអាចជាការងារមួយសំខាន់។ ក្នុងប្រទេសសមាជិកអាស៊ាន មានក្រសួង និងស្ថាប័នផ្សេងៗជាច្រើន ដែលមានតួនាទី ឬការទទួលខុសត្រូវ ពាក់ព័ន្ធនឹងកា រគ្រប់-គ្រងតំបន់ដីមមោក។ ដើម្បីធានាឲ្យបាន នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធ-ភាពប្រហែលជាត្រូវមានការពង្រឹងការសម្របសម្រួល ឬក៏ពង្រឹង ប្រសិទ្ធភាពការងារ។

## 1.5 បញ្ហា និងការព្រួយបារម្ភទូទៅ

បញ្ហា និងការព្រួយបារម្ភទូទៅដូចខាងក្រោម ត្រូវបានកំណត់ឡើងដោយផ្អែកលើឯកសារតាមប្រទេស និងការពិភាក្សា នៅសិក្ខាសាលាស្ដីអំពី APMI ក៏ដូចជាកិច្ចប្រជុំថ្នាក់តំបន់ផ្សេងៗ។

### *ក. អគ្គីភ័យក្នុងតំបន់ដីមមោក និងការបំពុលផ្សែងអ័ព្ទឆ្លងដែន*

បញ្ហាការគ្រប់គ្រងសំខាន់បំផុត ដែលមានសារៈសំខាន់ថ្នាក់តំបន់ គឺបញ្ហាការបំពុលផ្សែងអ័ព្ទឆ្លងដែនបង្កដោយអគ្គីភ័យតំបន់ដីមមោក ដែលភាគច្រើនបង្កដោយសកម្មភាពរបស់មនុស្ស។ តំបន់ដី មមោក ដែលមិន មានការបង្ហូរទឹកចេញកម្រនឹងទទួលរងអគ្គីភ័យណាស់ ដូច្នេះហើយការបង្ហូរទឹកចេញពីតំបន់ដីមមោក សម្រាប់ធ្វើកសិកម្ម វិស័យព្រៃឈើ និង សម្រាប់គោលបំណងផ្សេងៗទៀត គឺជាដើមចមដំបូង នៃអគ្គីភ័យក្នុងតំបន់ដីមមោក។ ហេតុការណ៍ធ្ងន់ធ្ងរបំផុតនៃអគ្គីភ័យ ក្នុងវាលទំនាបតំបន់ដីមមោក នាទសវត្សរ៍ចុងក្រោយនេះ គឺអគ្គីភ័យយ៉ាងសន្ធោសន្ធៅនៅក្នុងឆ្នាំ១៩៩៧-១៩៩៨ ដែលបានបំផ្លិចបំផ្លាញផ្ទៃដីតំបន់ទេសភាព ក្នុង តំបន់ដីមមោកយ៉ាងធំធេងនៅ

អំឡុងពេលរដូវប្រាំង។ អគ្គីភ័យអំឡុងឆ្នាំ១៩៩៧ -១៩៩៨ បាន ធ្វើឲ្យប្រទេសអាស៊ីអាគ្នេយ៍ពោរពេញដោយផ្សែងនិងផ្សែងអ័ព្ទ បានបំផ្លិចបំផ្លាញ និងធ្វើឲ្យសឹករេចរឹលតំបន់ដីមមោកចំនួន ២ លានហិកតា ក៏ដូចជាបង្កឲ្យមានការគម្រាមកំហែងដល់ធនធានធម្មជាតិ និងមុខងារប្រព័ន្ធអេកូឡូស៊ី របស់តំបន់ដីមមោករចនាសម្ព័ន្ធ និងលំនៅដ្ឋានក្នុងតំបន់ រួមនឹងការបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស។

### *ខ. ជីវភាពសហគមន៍*

តំបន់ដីមមោកដើរតួនាទីយ៉ាងសំខាន់ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន ហើយក្នុងនោះតំបន់ដីមមោកត្រូវបានប្រើប្រាស់ សម្រាប់ការប្រមូលរុក្ខជាតិឱសថ ការប្រមូលអនុផលព្រៃឈើ និងការធ្វើកសិដ្ឋាន។ល។ សកម្ម -ភាពទាំងនេះអាចបង្កឲមានផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនតូចដល់តំបន់ដីមមោក ដូចជាការសឹករេចរឹលជាដើម។

### *គ. ការប្រើប្រាស់តំបន់ដីមមោ ក និងធនធានរបស់តំបន់មមោ ក លើសកម្រិត*

ការបំលែងដីតំបន់ដីមមោក សម្រាប់ធ្វើចំការ ធ្វើកសិកម្ម និងអភិវឌ្ឍទីក្រុងគឺជាបញ្ហាមួយកើតឡើងក្នុងទ្រង់ទ្រាយធំ។ ផលវិបាកកើតឡើងដោយសកម្មភាពទាំងនេះ មានដូចជាការបង្ហូរទឹកចេញលើសប្រមាណ ការបាត់បង់ជីវចម្រុះ ការបំពុលដោយសារអគ្គីភ័យ និងផ្សែងអ័ព្ទ ដែលចូលរួមចំណែកដល់ការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។ លើសពីនេះ ការកាប់ឈើដោយខុសច្បាប់ក៏ជាបញ្ហាមួយចំបង ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់តំបន់ដីមមោក។ ទន្ទឹមនឹងនោះ ការកាប់ឈើធំៗ និងការដកហូតអនុផលព្រៃឈើក៏ជាកត្តាមួយគម្រាមកំហែងដល់តំបន់ដីមមោកផងដែរ។

### *ឃ. ការបង្ហូរទឹកចេញ*

រាល់ការអភិវឌ្ឍន៍ ក្នុងតំបន់ដីមមោកគឺសុទ្ធតែមានការបង្ហូរទឹកចេញពីក្នុងតំបន់ ឬមួយក៏បង្កឲមានការផ្លាស់ប្តូរតុល្យភាពជលសាស្ត្រនៅតំបន់ជុំ - វិញ។ ការបង្ហូរទឹកចេញនេះអាចបង្កឲ្យមានហានិភ័យ នៃការបង្ហូរទឹកលើសបរិមាណ ឬភាពស្ងួតហួតហែងលើសកម្រិត ដែលអាចបណ្តាលឲមានការខូចខាតមិនអាចកែប្រែបាន ឬមួយមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សហាគមន៍ធម្មជាតិ។ បន្ថែមពីនេះ ភាពរាំងស្ងួតខ្លាំង ក៏អាចបង្កឲមានអគ្គីភ័យ ក្នុងតំបន់ដីមមោកផងដែរ។

### *ង. ការបាត់បង់ជីវៈចម្រុះ*

ភាពសឹករេចរឹល នៃតំបន់ដីមមោក ដោយសារការកាប់ឆ្ការដី ការបង្ហូរទឹក និងការកើនឡើង នៃអគ្គីភ័យ បានបង្កឲជីវៈចម្រុះក្នុងតំបន់ដីមមោ កក្នុងតំបន់ទទួលរងការបាត់បង់។ ការបាត់បង់ជីវៈចម្រុះ ក្នុងតំបន់ដីមមោកក៏អាចបង្កឡើងដោយការប្រើប្រាស់ហួសប្រមាណ នៃប្រភេទឈើ ហ៊ុប និងរុក្ខជាតិសម្រាប់ធ្វើឱសថផងដែរ។

### *ច. ការបាត់បង់កាបោន*

បរិមាណកាបោនសរីរាង្គក្នុងតំបន់ដីមមោក បានធ្វើឲ្យតំបន់នេះដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្តុកកាបោន។ តាមការប៉ាន់ស្មាន តំបន់ដីមមោ កអាចស្តុកកាបោនរហូតដល់ទៅ ៥% នៃកាបោនស្តុក លើផ្ទៃរបស់ផែនដីទាំង - មូល។ នាពេលបច្ចុប្បន្ននេះ ការកាប់ឆ្ការ ការបង្ហូរទឹក និងការដុតតំបន់ដីមមោកបានបង្កឲ្យមានការបំភាយកាបោនយ៉ាងច្រើន ដែលជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ សម្រាប់ពិភពលោក។

### *ឆ. ការកកើតឡើង នូវកត្តាចង្រៃ និងជម្ងឺ*

ប្រព័ន្ធអេកូឡូស៊ីតំបន់ដីមមោក ដែលមានការផ្លាស់ប្តូរងាយទទួលរងការឈ្លានពានរបស់ប្រភេទក្រៅស្រុក និងការបង្កជម្ងឺ។

### ផ. កង្វះខាតចំណេះដឹង ស្តីអំពីការគ្រប់គ្រងតំបន់ដីមមោក

ឧបសគ្គមួយដ៏ចំបង សម្រាប់ការគ្រប់គ្រងតំបន់ដីមមោ ក នោះគឺ កង្វះខាតចំណេះដឹង ស្តីអំពីមុខងាររបស់តំបន់ដីមមោ ក និងជម្រើស ក្នុងការគ្រប់គ្រងប្រកបដោយនិរន្តរភាព។ ក្រៅពីឧទាហរណ៍មួយចំនួន ដែលបានរៀបរាប់ខាងលើ ការយល់ដឹងអំពីភាពស្មុគ្រស្មាញ និងមុខងាររបស់តំបន់ដីមមោក និង/ឬការគណនាជាតួលេខ នៃប្រព័ន្ធអេកូឡូស៊ីនេះ គឺនៅមានកម្រិតតិចតួចនៅឡើយ បើប្រៀបធៀបនឹងប្រព័ន្ធអេកូឡូស៊ីដទៃទៀត។ ទន្ទឹមនឹងនេះ ព័ត៌មានសមស្រប សម្រាប់ការវាយតម្លៃផលវិបាក ចំពោះប្រព័ន្ធអេកូឡូស៊ី ដោយសារការអភិវឌ្ឍន៍តំបន់ដីមមោ កមិនទាន់មានគ្រប់គ្រាន់នៅឡើយ។ ចំណេះដឹង ស្តីអំពីភាពស្មុគ្រស្មាញរបស់ប្រព័ន្ធអេកូឡូស៊ី នៃតំបន់ដីមមោក និងការរៀបរាប់ឲ្យបានទូលំទូលាយ នៃមុខងារពីធម្មជាតិ ក៏នៅមានកម្រិតផងដែរ។

### ឈ. លិខិតបទដ្ឋានច្បាប់ និងគោលនយោបាយនាពេលបច្ចុប្បន្ន

នាពេលបច្ចុប្បន្ន តំបន់ដីមមោ កក្នុងតំបន់ទទួលរងផលប៉ះពាល់ពីគោលនយោបាយ ដែលមិនមានភាពសមស្រប និងមិន ស៊ីសង្វាក់គ្នា។ ឧទា - ហរណ៍ ប្រទេសមួយចំនួនក្នុងតំបន់បានលើកទឹកចិត្ត ឲ្យមាន ការបង្ហូរទឹកចេញពីតំបន់ដីមមោក សម្រាប់ធ្វើកសិកម្ម បើទោះជាតំបន់ដីមមោ កផ្តល់អត្ត- ប្រយោជន៍តិចតួច សម្រាប់វិស័យកសិកម្មក៏ដោយ ឬមួយទោះបីជា ការផ្តល់សេវាកម្មផ្នែកអេកូឡូស៊ីតាមលក្ខណៈធម្មជាតិ មានតម្លៃច្រើនជាងក៏ដោយ។ បន្ថែមពីនេះទៀត ទោះបីជាមានច្បាប់ សម្រាប់ការពារតំបន់ដីមមោ កក្តីក៏ការអនុវត្តច្បាប់ជាទូទៅនៅមានកម្រិតទាប។

### ញ. បញ្ហានិយមន័យ

បញ្ហាមួយ ពាក់ព័ន្ធនឹង ការគ្រប់គ្រងតំបន់ដីមមោក ក្នុងតំបន់នោះ គឺ កង្វះខាតនិយមន័យរួម និងការបែងចែកតំបន់ដីមមោ កនៅក្នុងតំបន់។ បញ្ហា

នេះបង្កឲមានបញ្ហាមួយទៀត គឺការបែងចែកតំបន់ដីមមោកឲបានច្បាស់លាស់ និងការបង្កើត នូវគោលការណ៍ណែនាំ សម្រាប់ការគ្រប់គ្រងរួម។

## 1.6 តម្រូវការទូទៅពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក

ក្នុងតំបន់អាស៊ានមានបញ្ហាប្រហាក់ប្រហែលគ្នា ទាក់ទងនឹងការគ្រប់គ្រងតំបន់ដីមមោក ក្នុងនោះមានអគ្គីភ័យ ការបង្ហូរទឹក ការគ្រប់គ្រងមិនបានសមរម្យ និងជម្រើសជីវភាពដោយមាននិរន្តរភាព។ល។ លើសពីនេះ ប្រទេសសមាជិកអាស៊ាន ក៏មានលក្ខណៈប្រហាក់ប្រហែលគ្នា ក្នុងទិដ្ឋភាពរួមជាច្រើន ដូចជាតម្រូវការបន្ទាន់ផ្នែកចំណេះដឹង/ការអប់រំ/ការផ្លាស់ប្តូរ ព័ត៌មាន/ការកសាងសមត្ថភាព/វគ្គបណ្តុះបណ្តាល ការគ្រប់គ្រង និងទប់ស្កាត់ អគ្គីភ័យ ការប្រើប្រាស់ដោយមាននិរន្តរភាព ការស្តារ ការធ្វើសារពើភណ្ឌ ការស្រាវ - ជ្រាវ និងការអនុវត្តគម្រោងគម្រូ ឬគម្រោងសាកល្បង ។

ដើម្បីជំនះ នូវបញ្ហាទូទៅពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោ ក ចំណុចមួយចំនួនដូចខាងក្រោមគួរតែសម្រេចឲ្យបាន:

- លើកកម្ពស់ចំណេះដឹង ពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ីតំបន់ដីមមោក (ដោះស្រាយបញ្ហា និយមន័យ ការបង្កើតនូវជម្រើសសម្រាប់ការស្តារ និងការអភិវឌ្ឍ ការស្រាវជ្រាវ ការតាមដានឲ្យជាប់លាប់ និងការចែករំលែកព័ត៌មាន)
- ដោះស្រាយជម្លោះផលប្រយោជន៍ រវាងសហគមន៍មូលដ្ឋាន ឧស្សាហកម្ម រដ្ឋាភិបាល (ត្រូវគិតពីគ្នាទៅវិញទៅមក) ដោយមានបញ្ចូលការលើកកម្ពស់ចំណេះដឹងសហគមន៍
- កែលំអគោលនយោបាយ និងក្របខ័ណ្ឌច្បាប់

### *ក. លើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រ*

១. ដោះស្រាយបញ្ហានិយមន័យ

២. ការស្រាវជ្រាវ និងការតាមដានកំពុងដំណើរការៈ គម្រោងគម្រូ និងគម្រោងសាកល្បង

*ខ. ការលើកកម្ពស់ចំណេះដឹង និងការកសាងសមត្ថភាព*

១. ការអប់រំ
២. លើកកម្ពស់ការផ្លាស់ប្តូរព័ត៌មាន និងភាពសមស្រប នៃព័ត៌មាន
៣. វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា
៤. លើកកម្ពស់ការគ្រប់គ្រងតំបន់ដីមមោកដោយសហ-គមន៍ ដូចជាការផ្តល់ជម្រើសជីវភាព ដែលមាននិរន្តរភាពដល់ប្រជាសហគមន៍

*គ. លើកកម្ពស់ភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ*

១. ដោះស្រាយជម្លោះផលប្រយោជន៍ រវាងរដ្ឋាភិបាល និងស្ថាប័នក្រៅរដ្ឋាភិបាល

*ឃ. លើកកម្ពស់លិខិតបទដ្ឋានច្បាប់ និងគោលនយោបាយ*

១. ដោះស្រាយបញ្ហាការប្រើប្រាស់តំបន់ដីមមោ ក និង ធនធានក្នុងតំបន់
២. លើកកម្ពស់ការអនុវត្តច្បាប់

## 1.7 សហប្រតិបត្តិការក្នុងតំបន់

### *ក. ទស្សនវិស័យអាស៊ានឆ្នាំ ២០២០*

កិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីបរិស្ថាន អនុវត្តតាមទស្សនវិស័យអាស៊ានឆ្នាំ ២០២០ ផែនការសកម្មភាពរយៈពេលមធ្យម និងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ស្តីពីបរិស្ថាន។ ទស្សន ទានអាស៊ាន ឆ្នាំ ២០២០ បញ្ជាក់យ៉ាងច្បាស់លាស់ថាត្រូវមាន "អាស៊ានស្អាត និងមានពណ៌បៃតង តាមរយៈការបង្កើត

ឡើង នូវយន្តការមួយច្បាស់លាស់ សម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរ-ភាព ដែលធានាឲ្យបាន នូវកិច្ចការពារបរិស្ថានក្នុងតំបន់ និរន្តរភាពធនធានធម្មជាតិ និងគុណភាពជីវិតរបស់ប្រជាជនមានកម្រិតខ្ពស់”។

### *ខ. កិច្ចព្រមព្រៀងទីក្រុងបាលី លើកទីពីរ*

នៅសន្និបាតអាស៊ានលើកទី ៩ ក្នុងខែតុលា ឆ្នាំ២០០៣ ថ្នាក់ដឹកនាំអាស៊ានបានសន្យាថាត្រូវសម្រេចឲបាននូវសហគមន៍អាស៊ានត្រឹម ឆ្នាំ២០២០ ដោយផ្តោតលើវិស័យ ៣ សំខាន់: "សហគមន៍សន្តិសុខអាស៊ាន" "សហគមន៍សេដ្ឋកិច្ចអាស៊ាន" និង "សហគមន៍សង្គមវប្បធម៌អាស៊ាន" ដូចបានចែងក្នុងសេចក្តីប្រកាសកិច្ចព្រមព្រៀងអាស៊ានលើកទី ២ (កិច្ចព្រមព្រៀងអាស៊ានលើកទី ២)។ សហគមន៍សង្គមវប្បធម៌អាស៊ានបានបង្កើតឡើងស្របនឹងគោលដៅបង្កើតឡើងដោយទស្សនវិស័យអាស៊ាន ២០២០ ដែលក្នុងនោះប្រទេសអាស៊ានត្រូវរួបរួមគ្នា ក្នុងភាពជាដៃគូជាសហគមន៍មួយមាន សាមគ្គីភាព។ តាមរយៈសហគមន៍សង្គមវប្បធម៌អាស៊ាន កិច្ចសហការលើប្រជាជនតាមទីជនបទ និងផ្នែកសង្គមនឹងត្រូវបានពង្រឹង ហើយការរិះរក ដើម្បីឲ្យមានការចូលរួមពីគ្រប់វិស័យ រួមមានស្ត្រី យុវវ័យ និងសហគមន៍នឹងត្រូវធ្វើឡើង។ សហគមន៍សង្គមវប្បធម៌អាស៊ានក៏នឹងធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកំណើនប្រជាជន ការអប់រំ ភាពគ្មានការងារធ្វើ ការទប់ស្កាត់ជម្ងឺឆ្លង ដូចជាមេរោគហ៊ីវ/អេដស៍ និងជម្ងឺសារ ភាពសឹករេចរឹលនៃបរិស្ថាន និងការបំពុលឆ្លងដែនជាដើម។

### *គ. ក្រុមការងារបច្ចេកទេសបរិស្ថាន -ផ្សែងអ័ព្ទ ( ASOEN-HTTF) និងការប្រយុទ្ធប្រឆាំងនឹងអគ្គីភ័យថ្នាក់អនុតំបន់សម្រាប់ស៊ូមាត្រា និងបូនីអូ*

ASOEN-HTTF គឺជាផ្នែកមួយបន្ថែម នៃក្រុមការងារឧត្តមមន្ត្រីអាស៊ានស្តីពីបរិស្ថាន (ASOEN)។ ក្រុមការងារនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥។

ASOEN-HTTF មានប្រទេសឥណ្ឌូនេស៊ីជាប្រធាន ហើយមានសមាជិកភាពពីឧត្តមមន្ត្រីប្រទេសអាស៊ានទាំង ១០។

ដោយយល់ឃើញពីតម្រូវការជាចាំបាច់ ក្នុងការគ្រប់គ្រងអគ្គីភ័យនៅតាមទីតាំងជាក់លាក់ ក្នុងខែមេសា ឆ្នាំ១៩៩៨ ASOEN-HTTF បានបង្កើតនូវក្រុមការងារចំនួន ២ សម្រាប់អនុតំបន់សូមាត្រា និង បូនីអូ រួមមានក្រុមការងារចាត់ចែងប្រយុទ្ធនឹងអគ្គីភ័យថ្នាក់អនុតំបន់សូមាត្រា (SRFA Sumatra) និងក្រុមការងារប្រយុទ្ធប្រឆាំងនឹងអគ្គីភ័យថ្នាក់អនុតំបន់បូនីអូ (SRFA Borneo)។ បន្ទាប់មក ASOEN HTTF បានបង្កើតនូវក្រុមការងារ ២ បន្ថែមទៀត ដែលទទួលបន្ទុកលើការងារច្បាប់ និងការអនុវត្តច្បាប់ ( SRFA ក្រុមអ្នកច្បាប់ ដែលទទួលបន្ទុកការងារច្បាប់ និងការអនុវត្តច្បាប់) និងក្រុមការងារពិនិត្យលក្ខខណ្ឌបរិយាកាស និងឧតុនិយម (កិច្ចប្រជុំត្រួតពិនិត្យឡើងវិញលើបរិយាកាសអនុតំបន់)។ ក្រុមការងារមួយជាក់លាក់ ដែលមានឈ្មោះថា គណៈកម្មាធិការរៀបចំម៉ូឌែល ( SOC) គឺសម្រាប់រៀបចំម៉ូឌែលគ្រោះមហន្តរាយបង្កដោយផ្សែងអ័ព្ទ និងអគ្គីភ័យ។ SRFA ត្រូវបានបង្កើតឡើង ក្នុងខែសីហា ឆ្នាំ២០០២ ដើម្បីបង្កើតឡើង នូវទម្រង់ការដំណើរការតាមស្តង់ដារ សម្រាប់ SRFA និងរៀបចំសេចក្តីលម្អិត សម្រាប់ម៉ូឌែលរបស់ SRFA។

## *ឃ. ផែនការសកម្មភាពផ្សែងអ័ព្ទតំបន់អាស៊ាន*

ផែនការសកម្មភាពការងារផ្សែងអ័ព្ទអាស៊ានថ្នាក់តំបន់ (RHAP) ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីបរិស្ថានអាស៊ាន ក្នុងខែធ្នូ ឆ្នាំ១៩៩៧ អំឡុងពេលមានអគ្គីភ័យ និងការបំពុលឆ្លងដែនយ៉ាងធ្ងន់ធ្ងរ។ ក្រោមក្របខ័ណ្ឌទូទៅរបស់ RHAP វិធានការ និងសកម្មភាពយុទ្ធសាស្ត្រ គឺផ្តោតលើការពង្រឹងសមត្ថភាព និងលទ្ធភាពថ្នាក់តំបន់ ក្នុងការដោះស្រាយបញ្ហាការបំពុលផ្សែងអ័ព្ទឆ្លង

ដែន។ RHAP មានគោលបំណង ៣ ចំបង ដូចជា (១) ទប់ស្កាត់អគ្គីភ័យលើដី និងព្រៃឈើ តាមរយៈការពង្រឹងគោលនយោបាយ និងការអនុវត្តការគ្រប់គ្រងឲ្យបានកាន់តែប្រសើរឡើង (២) បង្កើត នូវយន្តការ ក្នុងការពិនិត្យអគ្គីភ័យលើដី និងព្រៃឈើ និង (៣) ពង្រឹងសមត្ថភាពក្នុងការប្រឆាំងនឹងអគ្គីភ័យលើដី និងព្រៃឈើ រួមនឹងវិធានការកាត់បន្ថយផ្សេងៗ។

ក្នុងនោះ RHAP បានបែងចែកជាបីផ្នែកសំខាន់ រួមមានការទប់ស្កាត់ ការកាត់បន្ថយ និងការតាមដាន។ ការដឹកនាំតាមផ្នែកទាំងបីនេះ ធ្វើឡើងដោយប្រទេសផ្សេងៗគ្នា។ ប្រទេសម៉ាឡេស៊ីទទួលបន្ទុកលើការទប់ស្កាត់។ ប្រទេសឥណ្ឌូនេស៊ីទទួលបន្ទុក ក្នុងការកាត់បន្ថយ និងប្រទេសសឹង្ហបុរីទទួលបន្ទុក ក្នុងការតាមដានអគ្គីភ័យ និងផ្សែងអ័ព្ទ។ ប្រទេសសមាជិកអាស៊ានក៏ទទួលបន្ទុក ក្នុងការអនុវត្តសកម្មភាពថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងផ្នែកផ្សេងៗរបស់ RHAP ផងដែរ។ ការអនុវត្ត RHAP ថ្នាក់តំបន់ និងអនុតំបន់ដើរតួនាទីជាកាតាលីករ និងជាការបំពេញបន្ថែមដល់វិធានការអនុវត្តថ្នាក់ជាតិ។

## *ង. កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន*

កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែនត្រូវបានចុះហត្ថលេខាដោយប្រទេសសមាជិកអាស៊ានទាំង ១០ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ កិច្ចព្រមព្រៀងមានចែងអំពីការតាមដាន ការវាយតម្លៃ និងការទប់ស្កាត់ កិច្ចសហប្រតិបត្តិការ បច្ចេក-ទេស និងការស្រាវជ្រាវវិទ្យាសាស្ត្រ យន្តការ សម្រាប់សម្របសម្រួលមធ្យោ - បាយទំនាក់ទំនង និងការបង្កភាពងាយស្រួល នៃទម្រង់ការគយ និង អន្តោរ-ប្រវេសន៍ សម្រាប់ការដោះស្រាយបញ្ហាគ្រោះមហន្តរាយ។ កិច្ចព្រមព្រៀង

ក៏បានលើកឡើង នូវការបង្កើតឡើង នូវមជ្ឈមណ្ឌលសម្របសម្រួលការគ្រប់-គ្រងបំពុលផ្សែងអ័ព្ទឆ្លងដែន។

កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅខែវិច្ឆិកា ឆ្នាំ២០០៣។ មកទល់ពេលបច្ចុប្បន្ន ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម ប្រទេសឡាវ ប្រទេសម៉ាឡេស៊ី ប្រទេសភូមា ប្រទេសសឹង្ហបុរី និងប្រទេសថៃបានអនុម័តលើកិច្ចព្រមព្រៀង ហើយបានតម្កល់ឯកសារ របស់ខ្លួនរង់ចាំការអនុម័តពីលេខាធិការដ្ឋានអាស៊ាន។

## *ច. គំនិតផ្ដួចផ្ដើមការគ្រប់គ្រងតំបន់ដីមរោគអាស៊ាន*

ទស្សនទាន សម្រាប់គំនិតផ្ដួចផ្ដើមនេះបានធ្វើឡើង ដោយមានកិច្ចពិភាក្សាជាមួយស្ថាប័នជាច្រើន នាឆ្នាំ១៩៩៩-២០០១។ ព័ត៌មាន ស្ដីពីអគ្គីភ័យ និងតម្រូវការ សម្រាប់កិច្ចសហប្រតិបត្តិការ ត្រូវបានលើកយកមក ពិភាក្សា នៅកិច្ចប្រជុំ ASOEN-HTTF លើកទី១៣ និងកិច្ចប្រជុំ AMMH លើកទី៧ ក្នុងខែកក្កដា ឆ្នាំ១៩៩៩។ កិច្ចប្រជុំ ASOEN-HTTF លើកទី១៩ និងកិច្ចប្រជុំ AMMH លើកទី៩ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១ -១២ ខែមិថុនា ឆ្នាំ២០០២ បានធ្វើការពិភាក្សាលើបញ្ហាការទប់ស្កាត់ និងគ្រប់គ្រងអគ្គីភ័យ ក្នុងតំបន់ដីមរោគ។

កិច្ចប្រជុំ AMMH លើកទី៩ ក៏បានធ្វើការពិភាក្សាលើការអភិវឌ្ឍន៍ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព នៃ តំបន់ដីមរោគក្នុងតំបន់ ហើយបានស្នើឲ HTTF និងក្រុមការងាររបស់ខ្លួនរិះរកការជម្រុញគំនិតផ្ដួចផ្ដើមនេះ។ APMI ត្រូវបានយកមកធ្វើការពិភាក្សា និងអភិវឌ្ឍបន្ថែម តាមរយៈការប្រឹក្សាយោបល់ បញ្ជីរសំណួរ និងកិច្ចប្រជុំថ្នាក់តំបន់ ហើយបានអនុម័តក្នុងខែកុម្ភៈ ឆ្នាំ២០០៣ នៅក្នុងកិច្ចប្រជុំ ASOEN-HTTF លើកទី២០ ក្នុងទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន រួមជាមួយនឹងផែនការការងារ សម្រាប់ឆ្នាំ២០០៣ -២០០៥។

APMI ត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំ AMMH លើកទី១០ ក្នុងខែមីនា ឆ្នាំ២០០៣ ក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា។

**គោលដៅ និងគោលបំណងរបស់APMI**

គោលដៅរបស់ APMI គឺធ្វើការលើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោ ក ក្នុងតំបន់អាស៊ាន តាមរយៈសកម្មភាពរួម ក៏ដូចជាលើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងគោលបំណងគាំទ្រ និងធ្វើឲ្យជីវភាពរស់នៅមូលដ្ឋានមាននិរន្តរភាព កាត់បន្ថយហានិភ័យ នៃអគ្គីភ័យ និងផ្សែងអ័ព្ទក្នុងតំបន់ ដែលអាចពាក់ព័ន្ធនឹងការចូលរួមចំណែកដល់ការគ្រប់គ្រងបរិស្ថាន។

គោលបំណងរបស់ APMI គឺត្រូវ:

- លើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពពាក់ព័ន្ធនឹងបញ្ហាការគ្រប់គ្រងតំបន់ដីមមោកក្នុងតំបន់
- កាត់បន្ថយអព្ភូតហេតុ នៃអគ្គីភ័យតំបន់ដីមមោ ក និងផ្សែងអ័ព្ទដែលកើតមានឡើង
- ធ្វើការគាំទ្រដល់សកម្មភាពអនុវត្តថ្នាក់ជាតិ និងមូលដ្ឋាន ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក និងការទប់ស្កាត់អគ្គីភ័យ
- ធ្វើការបង្កើតឡើង នូវយុទ្ធសាស្ត្រថ្នាក់តំបន់ និងយន្តការសហការដើម្បីជម្រុញការគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព

# 2 យុទ្ធសាស្ត្រថ្នាក់តំបន់ សម្រាប់ការគ្រប់គ្រងតំបន់ដីមមោក

## 2.1 សារតារបស់យុទ្ធសាស្ត្រ

សិក្ខាសាលាលើកទី ១ ស្តីពី APMI បានប្រព្រឹត្តិទៅនៅទីក្រុងបូហ្គោ ប្រទេសឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី១៦ -១៧ ខែតុលា ឆ្នាំ២០០៣ ដោយបានសម្រេចរួមគ្នាលើដំណើរការរៀបចំ APMS។ យុទ្ធសាស្ត្រព្រាងលើកទី១ ផ្អែកលើព័ត៌មានប្រមូលមកពីប្រទេសសមាជិកអាស៊ាន ដែលបានផ្តល់នៅក្នុងសិក្ខាសាលាថ្នាក់តំបន់លើកទី១ ស្តីពី APMI ក៏ដូចជាឯកសារពាក់ព័ន្ធផ្សេងៗ។ សេចក្តីព្រាងនេះត្រូវបានពិនិត្យយ៉ាងលម្អិតឡើងវិញ តាមរយៈកិច្ចប្រជុំប្រឹក្សាយោបល់ថ្នាក់ជាតិតាមបណ្តាប្រទេសអាស៊ាន ក៏ដូចជាសិក្ខាសាលាថ្នាក់តំបន់លើកទី២ ស្តីពី APMI ក្នុងខែឧសភា ឆ្នាំ២០០៥ ក្នុងទីក្រុងកូឡាឡាំពួរ។ ដំណើរការ នៃការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់តំបន់ក៏បានបញ្ចូលនូវការរៀបចំផែនការសកម្មភាពថ្នាក់ជាតិផងដែរ។

## 2.2 បញ្ហាប្រឈម សម្រាប់ការអភិរក្ស និងគ្រប់គ្រងតំបន់ដីមមោ កប្រកបដោយនិរន្តរភាព

អាស៊ីអាគ្នេយ៍មានផ្ទៃដីតំបន់ដីមមោកច្រើនជាង ២៥ លានហិកតា ដែលស្មើនឹង ៦០% នៃធនធានតំបន់ដីមមោ កត្រូពិកទូទាំងសាកលលោក។ តំបន់ដីមមោកក្នុងអាស៊ីអាគ្នេយ៍ទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងគាំទ្រជីវភាពរបស់សហគមន៍មូលដ្ឋាន។

តំបន់ដីមមោកដើរតួនាទីយ៉ាងសំខាន់ក្នុងវដ្តជលសាស្ត្រ ទីជម្រកសម្រាប់ជីវចម្រុះមានលក្ខណៈល្អដាច់គេ ការផ្គត់ផ្គង់ចំណីអាហារ (ជាពិសេសត្រីទឹកសាប និងផលិតផលធម្មជាតិផ្សេងៗ) ឈើហ៊ុប និងអនុផលព្រៃឈើ (ឧទាហរណ៍ ផ្តៅ និងឃ្មុំ) និងមុខងារ ក្នុងការរក្សាទុកកាបោន ប៉ុន្តែតួនាទីទាំងនេះជាទូទៅត្រូវបានបំភ្លេចចោល និងមានភាពធ្វេសប្រហែស ដោយសារ

មិនមានសមាហរណកម្ម នៃគោលនយោបាយ ក៏ដូចជាមាន មិនចុះសម្រុងគ្នា តាមវិស័យផ្សេងៗរួមមានវិស័យកសិកម្ម ជលផល រុក្ខកម្ម និងធនធានទឹក។

លើសពីនេះ ការកើនឡើង នូវសំពាធដល់ព្រៃនៅតំបន់ដីមមោ  កក្នុង តំបន់អាស៊ីអាគ្នេយ៍ ជាពិសេសសំពាធពីអ្នកមិនមានដីធ្លី និងផលិតកម្មអាហារ សម្រាប់តម្រូវការសេដ្ឋកិច្ចសង្គមកំពុងតែកើតមានឡើង។ ជាទូទៅប្រព័ន្ធ អេកូឡូស៊ី ដែលមានភាពផុយស្រួយងាយទទួលរងការគម្រាមកំហែងពី សកម្មភាពរបស់មនុស្ស ដែលបង្កឲមានភាពសឹករេចរឹលដោយផ្ទាល់ ឬដោយ ប្រយោល ហើយក្នុងករណីមួយចំនួនអាចទទួលរងផលប៉ះពាល់ជាអវិជ្ជមាន យ៉ាងខ្លាំង ដោយសារអគ្គីភ័យតំបន់ដីមមោ ក។ សកម្មភាពចំបង ដែលរំខាន ឬផ្លាស់ប្តូរលក្ខខណ្ឌតំបន់ដីមមោក និងធ្វើឲមានភាពខូចខាតប្រព័ន្ធអេកូឡូស៊ី គឺការបង្ហូរទឹកដោយមិនមាននិរន្តរភាព ការកាប់ឈើមិនមាននិរន្តរភាព និង ការកាប់រានដីទ្រង់ទ្រាយធំ។

## 2.3 សនិទានភាព សម្រាប់យុទ្ធសាស្ត្រថ្នាក់តំបន់

ការប្រឹងប្រែង និងសកម្មភាពជាច្រើន សម្រាប់ការអភិរក្ស និងគ្រប់គ្រង តំបន់ដីមមោកក្នុងតំបន់ គឺជាសកម្មភាពថ្នាក់ជាតិ និងជាសកម្មភាពមួយដាច់ ដោយឡែក។ នាពេលបច្ចុប្បន្ន មានកិច្ចសហប្រតិបត្តិការមួយចំនួនក្រោមកិច្ច សហប្រតិបត្តិការអាស៊ាន ប៉ុន្តែ  កិច្ចសហការ ហាក់ដូចជា  នៅមានកម្រិត នៅឡើយ។ ការងារដំបូងរបស់  SFRA, HTTF, AMMH។ល។ គឺផ្តោតជា សំខាន់លើការងារបន្ទាន់  ក្នុងការដោះស្រាយបញ្ហាអគ្គីភ័យ និងផ្សែងអ័ព្ទ ហើយមិនបានបញ្ចូលយុទ្ធសាស្ត្ររយៈពេលយូរអង្វែង ក្នុងការដោះស្រាយឲ្យ បានជាក់លាក់លើបញ្ហាតំបន់ដីមមោកក្នុងតំបន់ឡើយ។

នៅក្នុងតំបន់ មានលក្ខណៈប្រហាក់ប្រហែលគ្នាជាច្រើន ពាក់ព័ន្ធនឹង ការគ្រប់គ្រប់តំបន់ដីមមោក ដូចជាបញ្ហាទូទៅពាក់ព័ន្ធនឹងអគ្គីភ័យ ការបង្ហូរ

ទឹក ការអនុវត្តការគ្រប់គ្រងមិនបានត្រឹមត្រូវ និងជម្រើសជីវភាពប្រកបដោយនិរន្តរភាព។ល។ ហេតុនេះ APMI ត្រូវបានបង្កើតឡើង ក្នុងគោលបំណងផ្តល់នូវក្របខ័ណ្ឌ ក្នុងការជម្រុញការលើកកម្ពស់ការចូលរួម និងជម្រុញឲ្យអ្នកពាក់ព័ន្ធផ្សេងៗធ្វើការរួមគ្នា ដើម្បីពង្រីកគោលគំនិត និងចំណេះដឹងមូលដ្ឋាន ក៏ដូចជាបង្កើនការយល់ដឹង អំពីបញ្ហាសំខាន់ៗ នៅក្នុង និងរវាងក្រុមផ្សេងៗ ធ្វើការសម្របសម្រួលផ្លាស់ប្តូរព័ត៌មានសំខាន់ៗ និងចាំបាច់សម្រាប់ការគ្រប់គ្រងតំបន់ដីមមោកក្នុងតំបន់ និងពង្រីកវិសាលភាពកម្មវិធីការងារ។

ក្នុងន័យនេះ ធនធានកំពុងតែមានកម្រិតអាចត្រូវបានប្រើប្រាស់លើបញ្ហាទូទៅ និងអាចជៀសវាង នូវការធ្វើការជាន់គ្នា។ លើសពីនេះ វត្តមាននៃក្របខ័ណ្ឌ ដែលមានលក្ខណៈកាន់តែទូលំទូលាយនេះ នឹងអាចធានាបា ន ថាការកំណត់ចន្លោះ និងអាទិភាពសកម្មភាព សម្រាប់ការអភិរក្ស និងគ្រប់គ្រងតំបន់ដីមមោកក្នុងតំបន់នឹងត្រូវធ្វើឡើង។ បន្ទាប់មក យុទ្ធសាស្ត្រប្រកបដោយអត្តន័យ និងអាចអនុវត្តទៅបាន នឹងត្រូវបានធ្វើការសម្រេចរួមគ្នា ហើយអាចទទួលយកបាន សម្រាប់អ្នកពាក់ព័ន្ធ ដែលចូលរួមទាំងអស់ សម្រាប់ធ្វើការប្រើប្រាស់ដោយឈ្លាសវៃ និង ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោកក្នុងតំបន់។

បន្ថែមពីនេះ មានការរំពឹងទុកថាយុទ្ធសាស្ត្រនេះនឹងដើរតួនាទីជាមគ្គ - ទ្ទេសន៍ សម្រាប់បណ្តាប្រទេសក្នុងការចាត់វិធានការណ៍ ដែលអាចធានាឲ្យបាននូវការទប់ស្កាត់ និងគ្រប់គ្រងអគ្គីភ័យតំបន់ដីមមោ ក នៅក្នុងតំបន់ និងផ្សែងអ័ព្ទ ដែលកើតមាននាពេលអនាគត តាមរយៈការលើកកម្ពស់ ការគ្រប់-គ្រងតំបន់ដីមមោក។

## 2.4 គោលដៅ

គោលដៅ នៃយុទ្ធសាស្ត្រនេះ គឺធ្វើការជម្រុញឲ្យមានការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោកក្នុងប្រទេសអាស៊ាន តាមរយៈសកម្មភាពរួម និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រ និងធ្វើឲ្យមាននិរន្តរភាពជីវភាពមូលដ្ឋាន កាត់បន្ថយហានិភ័យ នៃអគ្គីភ័យ និងផ្សែងអ័ព្ទដែលពាក់ព័ន្ធ ក៏ដូចជាចូលរួមចំណែកដល់ការគ្រប់គ្រងបរិស្ថានពិភពលោក។

គោលដៅនេះស្របគ្នានឹងចក្ខុវិស័យអាស៊ានឆ្នាំ២០២០ ដែលចង់បាន "អាស៊ានស្អាត និងមានពណ៌បៃតង តាមរយៈការបង្កើតឡើង នូវយន្តការមួយច្បាស់លាស់ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលធានាឲ្យបាននូវកិច្ចការពារបរិស្ថានក្នុងតំបន់ និរន្តរភាពធនធានធម្មជាតិ និងគុណភាពជីវិតរបស់ប្រជាជនមានកម្រិតខ្ពស់"។

យុទ្ធសាស្ត្រថ្នាក់តំបន់នេះនឹងផ្តល់ នូវក្របខ័ណ្ឌរួមមួយ សម្រាប់អ្នកទទួលខុសត្រូវ ឬមានការប្តេជ្ញាចិត្ត ក្នុងការគ្រប់គ្រងប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដោយឈ្លាសវៃ ការទប់ស្កាត់អគ្គីភ័យ និងការស្តារឡើងវិញនៃតំបន់ដីមមោក។ យុទ្ធសាស្ត្រនេះកសាងបន្ថែមលើគោលការណ៍ សម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដែលមានចែងក្នុងសេចក្តីប្រកាស នៃកិច្ចព្រមព្រៀងលើកទី២ របស់អាស៊ាន (កិច្ចព្រមព្រៀងលើកទី២ ទីក្រុងបាលី) ។ យុទ្ធសាស្ត្រនេះ ក៏ចូលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍សង្គមវប្បធម៌អាស៊ាន (ASCC) ដែលមានបំណង ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាក្នុងតំបន់ រួមមានបញ្ហាពាក់ព័ន្ធនឹងការខូចខាត នៃបរិស្ថាន និងការបំពុលឆ្លងដែន។ យុទ្ធសាស្ត្រក៏ចូលរួមចំណែកផងដែរ ដល់ការអនុវត្តកិច្ចព្រមព្រៀង ស្តីអំពីការបំពុលផ្សែងអ័ព្ទឆ្លងដែន និងផែនការសកម្មភាពផ្សែងអ័ព្ទថ្នាក់តំបន់អាស៊ាន។

## 2.5 គោលបំណងទូទៅ

យុទ្ធសាស្ត្រ ដែលបានស្នើឡើងមានគោលបំណងទូទៅចំនួន៤រួមមាន:

*គោលបំណងទូទៅទី១៖ លើកកម្ពស់ចំណេះដឹង និងសមត្ថភាព ស្តីពីតំបន់ដីមមោក*

លើកកម្ពស់ចំណេះដឹង និងការយល់ដឹង ស្តីពីបញ្ហាតំបន់ដីមមោ ក និងពង្រឹងសមត្ថភាព ស្តីពីការប្រើប្រាស់ដោយឈ្លាសវៃ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោកនៅក្នុងតំបន់។

*គោលបំណងទូទៅទី២៖ ដោះស្រាយបញ្ហាការបំពុលផ្សែងអ័ព្ទឆ្លងដែន និងភាពសឹករេចរឹល នៃបរិស្ថាន*

ធ្វើការកាត់បន្ថយអព្ភូតហេតុ នៃអគ្គីភ័យតំបន់ដីមមោ ក និងបញ្ហាផ្សែងអ័ព្ទ ដែលពាក់ព័ន្ធនៅក្នុងតំបន់ និងធ្វើការលើកកម្ពស់ការទប់ស្កាត់ ការគ្រប់ - គ្រង និងការតាមដាន តាមរយៈការប្រឹងប្រែងរួមគ្នា តាម បណ្តាប្រទេសសមាជិកអាស៊ាន។

*គោលបំណងទូទៅទី៣៖ ជម្រុញការគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព*

ជម្រុញឲ្យមានការគ្រប់គ្រងតាមបែបសមាហរណកម្ម នៃតំបន់ដីមមោកក្នុងវិស័យរុក្ខកម្ម ទឹក កសិកម្ម ជីវភាពសហគមន៍ និងការស្តារឡើងវិញ នៃព្រៃឈើក្នុងវាលភក់តំបន់ដីមមោក ដែលទទួលការខូចខាត ឬមួយក៏ស្តារឡើងវិញ នូវតំបន់ដីមមោក ដែលទទួលរងការខូចខាត។

*គោលបំណងទូទៅទី៤៖ ជម្រុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់*

ជម្រុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ តាមរយៈការផ្លាស់ប្តូរ និងចែករំលែកព័ត៌មាន ការស្រាវជ្រាវ និងភាពជាដៃគូ ក្នុងការអនុវត្តសកម្មភាពក៏ដូចជាការគៀងគររកធនធាន។

## 2.6 ផែនការសកម្មភាព

គោលបំណងនីមួយៗខាងលើ ត្រូវសម្រេចដោយគោលបំណង និងសកម្មភាពប្រតិបត្តិ ដែលបែងចែកជា ១៣វិស័យបង្គោលផ្សេងៗគ្នា។ តារាងទី១ បង្ហាញពីវិស័យបង្គោល និងគោលដៅប្រតិបត្តិការតាមវិស័យ។

ផែនការសកម្មភាព សម្រាប់យុទ្ធសាស្ត្រ (មើលតារាងទី២) គឺត្រូវតែបង្កើតឡើង សម្រាប់ដំណើការការអនុវត្តយុទ្ធសាស្ត្រ។ ចំណុចសកម្មភាពជាក់លាក់ត្រូវបានកំណត់ឡើង តាមគោលបំណងប្រតិបត្តិ ដោយមានលំដាប់ និងពេលវេលាផ្សេងៗគ្នា។ លំដាប់ថ្នាក់ នៃការអនុវត្ត មាន ២ សំខាន់ រួមមាន (១) សកម្មភាពត្រូវអនុវត្តនៅថ្នាក់តំបន់ និង (២) សកម្មភាពដែលប្រទេសសមាជិកអាស៊ានគួរធ្វើការពិចារណារ ហើយបញ្ចូលទៅក្នុងផែនការសកម្ម - ភាពថ្នាក់ជាតិតាមប្រទេសនីមួយៗ។ សកម្មភាពថ្នាក់តំបន់អាចជាសកម្មភាពដែលលើកកម្ពស់ ឬបំពេញបន្ថែមដល់សកម្មភាពថ្នាក់ជាតិ តាមរយៈការចែករំលែកបទពិសោធន៍ ព័ត៌មាន និងចំណេះដឹង ការបង្កើតឡើងនូវបណ្តាញថ្នាក់តំបន់ និងវិធាន/យន្តការ/ស្តង់ដាថ្នាក់តំបន់រួមមួយ។ល។

| វិស័យបង្គោល | | គោលបំណងប្រតិបត្តិ |
|---|---|---|
| ១.ការធ្វើសារពើភ័ណ្ឌ និងការវាយតម្លៃ | ១.១ | ធ្វើការកំណត់ នូវវិសាលភាព និងស្ថានភាពនៃតំបន់ដីមោក ក្នុងតំបន់អាស៊ាន (រួមមានបញ្ហានិយមន័យ) |
| | ១.២ | វាយតម្លៃបញ្ហា និងឧបសគ្គប្រឈម ក្នុងការគ្រប់គ្រងតំបន់ដីមោក |

| | | |
|---|---|---|
| | ១.៣ | ធ្វើការតាមដាន និងវាយតម្លៃស្ថានភាព និងការគ្រប់គ្រងតំបន់ដីមមោក |
| ២. ការស្រាវជ្រាវ | ២.១ | អនុវត្តសកម្មភាពស្រាវជ្រាវជាអាទិភាព |
| ៣. លើកកម្ពស់ចំណេះដឹង និងការកសាងសមត្ថភាព | ៣.១<br><br><br><br><br><br>៣.២ | លើកកម្ពស់ចំណេះដឹងសាធារណៈ ស្តីអំពីសារៈសំខាន់តំបន់ដីមមោកភាពងាយរងគ្រោះ របស់ដីមមោកចំពោះអគ្គីភ័យ និងការគម្រាមកំហែងដោយសារផ្សែងអ័ព្ទ តាមរយៈការអនុវត្តផែនការទូលំទូលាយ<br><br>កសាងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក |
| ៤. ការចែករំលែកព័ត៌មាន | ៤.១ | លើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងជម្រុញការចែករំលែក |
| ៥. គោលនយោបាយ និងបទដ្ឋានច្បាប់ | ៥.១ | អភិវឌ្ឍ ឬពង្រឹងគោលនយោបាយ ឬបទដ្ឋានច្បាប់ក្នុងកិច្ចការពារតំបន់ដីមមោក និងកាត់បន្ថយអគ្គីភ័យតំបន់ដីមមោក |
| ៦. ការបង្ការ ការគ្រប់គ្រង និងការតាមដានអគ្គីភ័យ | ៦.១ | កាត់បន្ថយ និង ធានាឲ្យបានថា ការកើតឡើង នៃអគ្គីភ័យ និងផ្សែងអ័ព្ទ ដែលកើតមាន នៅកម្រិតអប្បបរមា |
| ៧. ការអភិរក្សជីវចម្រុះតំបន់ដីមមោក | ៧.១ | លើកកម្ពស់ការអភិរក្សជីវចម្រុះតំបន់ដីមមោក |
| ៨. ការគ្រប់គ្រងតំបន់ដីមមោក តាមបែបសមាហរណ | ៨.១<br><br><br>៨.២ | លើកកម្ពស់ការចូលរួម នៃស្ថាប័នចម្រុះក្នុងការគ្រប់គ្រងតំបន់ដីមមោក<br><br><br>លើកកម្ពស់ការគ្រប់គ្រងធនធានទឹក |

| | | |
|---|---|---|
| កម្ម | | និងតំបន់ដីមមោកតាមបែបសមាហរណកម្ម ដោយប្រើប្រាស់វិធានការគ្រប់គ្រងទូទាំងផ្ទៃអាង ហើយជៀសវាងការគ្រប់គ្រងដាច់ដោយឡែកពីគ្នា |
| | ៨.៣ | លើកកម្ពស់ការគ្រប់គ្រងព្រៃឈើ និងតំបន់ដីមមោកតាមបែបសមាហរណកម្ម |
| | ៨.៤ | ធ្វើការគ្រប់គ្រងវិស័យកសិកម្មតំបន់ដីមមោកតាមបែបសមាហរណកម្ម |
| | ៨.៥ | លើកកម្ពស់ជីវភាពសហគមន៍ និងការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហរណកម្ម |
| ៩. ជម្រុញឲ្យមានទីតាំងតំបន់ដីមមោកគម្រូសម្រាប់ការបង្ហាញ | ៩.១ | ជម្រុញឲមានការអនុវត្តការគ្រប់គ្រងល្អបំផុត |
| ១០. ការស្តាបនា និង ស្តារឡើងវិញ | ១០.១ | បង្កើត នូវបច្ចេកទេសសមស្រប សម្រាប់ការស្តារ ឬស្ថាបនាតំបន់ដីមមោកទទួលរងការខូចខាត |
| | ១០.២ | ធ្វើការស្តារឡើងវិញ នូវតំបន់ដីមមោក ទទួលរងអគ្គីភ័យ ទទួលរងការបង្ហូរទឹកចេញ និងមានភាពខូចខាត |
| ១១. តំបន់ដីមមោក និងការប្រែ | ១១.១ | ធ្វើការការពារ និងលើកកម្ពស់មុខងាររបស់តំបន់ដីមមោក |

| | | |
|---|---|---|
| ប្រែ លអាកាសធាតុ | ១១.២ | ក្នុងការស្រូប និងស្តុកទុកកាបោន<br><br>ធ្វើការគាំទ្រដល់ដំណើរការបន្សាំរបស់តំបន់ដីមមោកទៅនឹងការប្រែប្រួលអាកាសធាតុ |
| ១២. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ | ១២.១<br><br>១២.២<br><br>១២.៣<br><br>១២.៤ | ជម្រុញការផ្លាស់ប្តូរឯកទេស ក្នុងការដោះស្រាយបញ្ហានិងគ្រប់គ្រងតំបន់ដីមមោក<br><br>បង្កើត "មជ្ឈមណ្ឌលមានឧត្តមភាពក្នុងតំបន់" សម្រាប់ធ្វើការវាយតម្លៃ និងគ្រប់គ្រងតំបន់ដីមមោក<br><br>ចូលរួមចំណែកដល់ការអនុវត្តកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗ និងយន្តការប្រតិបត្តិការថ្នាក់តំបន់<br><br>លើកកម្ពស់ភាពជាដៃគូរាល់អ្នកពាក់ព័ន្ធចម្រុះក្នុងការគាំទ្រដល់ការគ្រប់គ្រងតំបន់ដីមមោក |
| ១៣. ផ្តល់ហិរញ្ញទានសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ | ១៣.១ | ធ្វើការគៀងគរធនធានហិរញ្ញវត្ថុត្រូវការចាំបាច់ សម្រាប់ការអនុវត្តកម្មវិធី និងសកម្មភាព ដើម្បីសម្រេចគោលដៅ របស់យុទ្ធសាស្ត្រ |

តារាងទី១៖ តារាងបង្ហាញអំពីវិស័យបង្គោល និងគោលដៅប្រតិបត្តិតាមវិស័យនីមួយៗ

ចំណុចគោលរបស់សកម្មភាពត្រូវអនុវត្តតាមដំណាក់កាលផ្សេងៗគ្នា។ រយៈពេល ដែលបានស្នើឡើង មាន ៣ សំខាន់ គឺ (១) S សម្រាប់រយៈពេលខ្លី

(២០០៥-២០១០) សម្រាប់សកម្មភាព ដែលត្រូវបញ្ចប់ក្នុងរយៈពេល ៥ឆ្នាំ (២) M សម្រាប់រយៈពេលមធ្យម សម្រាប់សកម្មភាពបញ្ចប់រយៈពេល ១០ឆ្នាំ និង (៣) L សម្រាប់រយៈពេលយូរអង្វែង (២០០៥ -២០២០) សម្រាប់សកម្មភាពបញ្ចប់នៅឆ្នាំ ២០២០ ដូច្នេះហើយសកម្មភាពនេះមិនចាំបាច់ចាប់ផ្តើមភ្លាមៗនោះទេ និង (៤) C សម្រាប់សកម្មភាពនៅបន្តគ្នា ដែលត្រូវអនុវត្តជាបន្តបន្ទាប់។

កម្រិត នៃអាទិភាពក៏ត្រូវបានចាត់ សម្រាប់សកម្មភាពនីមួយៗផងដែរ។ អាទិភាពមានកម្រិត ៣ផ្សេងគ្នា រួមមាន (១) L ទាប (២) M មធ្យម និង (៣) H ខ្ពស់។ ការចាត់អាទិភាព សម្រាប់ចំណុចសកម្មភាពនីមួយៗអា ចមានអត្ថប្រយោជន៍ ក្នុងករណី ដែល ធនធានមានកម្រិត សម្រាប់ការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ។ ការផ្តោតទៅកាន់តែជាក់លាក់ទៀតនោះគឺត្រូវគិតពីការសម្របសម្រួលរកប្រភពមូលនិធិ ហើយចាប់ផ្តើម ការអនុវត្តយុទ្ធសាស្ត្រថ្នាក់តំបន់។ ការចាត់ថ្នាក់អាទិភាព សម្រាប់សកម្មភាពថ្នាក់ជាតិក្នុងតារាង២នឹងអាចណែនាំផ្លូវដល់ប្រទេសសមាជិកអាស៊ាន ក្នុងការកំណត់អាទិភាពសកម្មភាពក្នុងផែនការសកម្មភាពថ្នាក់ជាតិរបស់ខ្លួន។

កាឡេានចុងក្រោយ នៃផែនការសកម្មភាពផ្តល់ នូវយោបល់ពាក់ព័ន្ធនឹងតម្រូវការ នៃការគាំទ្រ ដែលអាចធ្វើឡើង សម្រាប់សកម្មភាពនីមួយៗ។ កាឡេាននេះក៏បានផ្តល់ផងដែរ នូវយុទ្ធសាស្ត្រហិរញ្ញវត្ថុ និងការអនុវត្តសម្រាប់សកម្មភាពនីមួយៗ ដូចជាសកម្មភាពត្រូវការធនធានហិរញ្ញវត្ថុ (F) សកម្មភាពអាចធ្វើបានដោយអ្នកឯកទេស ឬធនធានក្នុងប្រទេសអាស៊ាន (AT) ឬក៏ត្រូវការធនធានពីប្រភពខាងក្រៅ (ET)។

ផែនការសកម្មភាពលម្អិត (DAP) គួរតែបង្កើតឡើង បន្ទាប់ពីមានការអនុម័តលើយុទ្ធសាស្ត្រថ្នាក់តំបន់។ DAP នឹងបង្ហាញ នូវព័ត៌មានលម្អិតរបស់

ថវិកា ប្រភពមូលនិធិ កាលបរិច្ឆេទគោលដៅ អង្គភាពអនុវត្ត និងអថេរ សម្រាប់ធ្វើការតាមដាន។ DAP គួរតែជាផែនការមួយមានលក្ខណៈបត់បែន ដែលអាចធ្វើការកែប្រែ និងធ្វើឲ្យមានបច្ចុប្បន្នភាពពីដំណាក់កាលមួយទៅដំណាក់មួយទៀត។ ផ្អែកលើសកម្មភាពបានអនុវត្ត/បានបញ្ចប់ ការ កែប្រែលើចំណុចគោលដៅរបស់សកម្មភាពនឹងអាចធ្វើឡើង ដោយមានការដាក់បញ្ចូល នូវសកម្មភាពថ្មី ហើយលប់ចោល នូវសកម្មភាពជាន់គ្នា។ រាល់ការផ្លាស់ប្តូរ ឬធ្វើឲមានបច្ចុប្បន្នភាពក្នុង DAP ត្រូវមានការរាយការណ៍ទៅស្ថាប័នអាស៊ាន ដែលពាក់ព័ន្ធ។ ការបង្កើតឡើង និងការធ្វើបច្ចុប្បន្នភាពរបស់ DAP សម្រាប់ APMS ត្រូវធ្វើតាមយន្តការ និងបែបបទគម្រូប្រើប្រាស់ ក្នុងការបង្កើតផែនការអនុវត្តលម្អិត (DIP) សម្រាប់ផែនការសកម្មភាពផ្សេងអំពីថ្នាក់តំបន់។ DAP មិនត្រឹមតែឆ្លុះបញ្ចាំងពីសកម្មភាពផ្តួចផ្តើម របស់ប្រទេសសមាជិកអាស៊ាន ឬអាស៊ាន ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំង នូវសកម្មភាពផ្តួចផ្តើមដោយម្ចាស់ជំនួយ ឬដៃគូ ដែលគាំទ្រដល់ការអនុវត្តចំណុចគោលដៅសកម្មភាពជាក់លាក់ណាមួយផងដែរ។

## 2.7 ផែនការសកម្មភាពថ្នាក់ជាតិ(NAPs)

សម្រាប់សកម្មភាពថ្នាក់ជាតិ ប្រទេសជាសមាជិកអាស៊ានគួររៀបចំផែនការសកម្មភាពថ្នាក់ជាតិរៀងៗខ្លួន សម្រាប់រយៈពេល ២០០៦ -២០២០ ដោយផ្អែកលើគោលដៅ និងគោលបំណងរបស់យុទ្ធសាស្ត្រថ្នាក់តំបន់។ NAPs គួរតែមានទំនាក់ទំនង និងបំពេញបន្ថែមលើយុទ្ធសាស្ត្រថ្នាក់តំបន់ ហើយយុទ្ធសាស្ត្រថ្នាក់តំបន់ក៏គួរតែមានទំនាក់ទំនង និងបំពេញបន្ថែមដល់ NAPs ផងដែរ។ សកម្មភាពអនុវត្ត ក្នុងNAPs គឺជាការងារមួយ ដែលប្រទេសសមាជិកអាស៊ានត្រូវធ្វើការសម្រេចចិត្ត តាមរយៈការប្រឹក្សាយោបល់ថ្នាក់ជាតិ។ ប្រទេសសមាជិកអាស៊ានគួរធ្វើការគិតគូរពីសមត្ថភាពអនុវត្ត រួមមានភាពសមស្របនៃធនធានហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍ NAPs។ ចំណែកឯ

ការតាមដាន និងវាយតម្លៃ NAPs តាមប្រទេសនីមួយៗ គួរតែធ្វើឡើង តាមរយៈស្ថាប័នអាស៊ាន ដែលពាក់ព័ន្ធ ដើម្បីធានាឲបាន នូវភាពពាក់ព័ន្ធគ្នា រវាង NAPs ទៅនឹងយុទ្ធសាស្រ្តថ្នាក់តំបន់។

*តារាងទី២៖ ផែនការសកម្មភាពយុទ្ធសាស្ត្រការគ្រប់គ្រងតំបន់ដីមមោអាស៊ាន*

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ១. ការធ្វើសារពើភ័ណ្ឌ និងការវាយតម្លៃ | ១.១៖ ធ្វើការកំណត់ នូវវិសាលភាព និងស្ថានភាពតំបន់ដីមមោក ក្នុងតំបន់អាស៊ាន (រួមមានបញ្ហានិយមន័យ) | ១.១.១ | ធ្វើឲមានសុខដុមនីយកម្មនិយមន័យ និងការបែងចែកតំបន់ដីមមោក (ឧទាហរណ៍ ប្រភេទជម្រៅ រុក្ខជាតិ របបទឹក និងវិសាលភាព) | C, R | S | H | AT |
| | | ១.១.២ | ធ្វើការកំណត់ និងធ្វើឲ្យមានបច្ចុប្បន្នភាព នៃវិសាលភាព និងស្ថានភាពតំបន់ដីមមោក ក្នុងតំបន់តាមរយៈការធ្វើសារពើភ័ណ្ឌថ្នាក់ជាតិឲបានទូលំទូលាយ (រួមមានស្ថានភាព នៃការការពារភាព | C,R | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | សឹករេចរឹល និងការប្រើប្រាស់ដី) | | | | |
| | | ១.១.៣ | ធ្វើការស្វែងយល់ឲ្យបានច្បាស់លាស់ពីការប្រើប្រាស់ផ្ទាល់ និងប្រយោល និងតម្លៃតំបន់ដីមមោក និងជីវចម្រុះ ដែលពាក់ព័ន្ធ | C,R | S | H | AT |
| | ១.២៖ វាយតម្លៃបញ្ហា និងឧបសគ្គប្រឈម ក្នុងការគ្រប់គ្រងតំបន់ដីមមោក | ១.២.១ | ធ្វើការកំណត់ នូវបញ្ហាឧបសគ្គ និងឱកាស ក្នុងការគ្រប់គ្រងតំបន់ដីមមោក | C, R | S | H | AT |
| | | ១.២.២ | ធ្វើការវាយតម្លៃបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក ដើម្បីធ្វើការកំណត់ នូវជម្រើសការគ្រប់គ្រង | C,R | M | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៣៖ ធ្វើការតាមដាន និង វាយតម្លៃស្ថានភាព និងការគ្រប់គ្រងតំបន់ដីមមោក | ១.៣.១ | ធ្វើការបង្កើតឡើង នូវគោលការណ៍ណែនាំ សម្រាប់ធ្វើការតាមដាន តំបន់ដីមមោក ពាក់ព័ន្ធនឹងការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ី និងគោលបំណង សម្រាប់ការគ្រប់គ្រង | R | S | M | AT, ET, F |
| | | ១.៣.២ | ធ្វើការអនុវត្តការតាមដាន តំបន់ដីមមោកឲ្យបាន ទៀងទាត់ រួមមានគុណភាពទឹកតំបន់ដីមមោក និងលក្ខខណ្ឌគីមីសាស្រ្ត និងរូបសាស្រ្ត | C | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. ការស្រាវជ្រាវ | ២.១ អនុវត្តសកម្មភាពស្រាវជ្រាវជាអាទិភាព | ២.១.១ | ធ្វើការស្រាវជ្រាវអំពីបច្ចេកទេស និងការអនុវត្តសមស្រប សម្រាប់ការគ្រប់គ្រងតំបន់ដីមមោក | C | M | H | AT, ET, F |
| | | ២.១.២ | ធ្វើការស្រាវជ្រាវជាមូលដ្ឋានអំពីប្រភេទ និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីមមោក និងដំណើរការជលសាស្ត្រ ដើម្បីធ្វើការស្វែងយល់អំពីមុខងារតំបន់ដីមមោកឲ្យបានកាន់តែប្រសើរឡើង | C, R | L | M | AT, ET, F |
| | | ២.១.៣ | ធ្វើការស្រាវជ្រាវ និងអភិវឌ្ឍ ដើម្បីលើកកម្ពស់ការប្រើប្រាស់មានស្រាប់ ឬបង្កើត នូវការប្រើប្រាស់ថ្មី សម្រាប់ផលិតផល និងធនធានតំបន់ដីមមោក | C | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. ការស្រាវជ្រាវ | | ២.១.៤ | ធ្វើការស្រាវជ្រាវ ដើម្បីវាយតម្លៃ និងគាំទ្រដល់ការអភិវឌ្ឍសហាគមន៍ និងជីវភាពរស់នៅដោយប្រើប្រាស់ចំណេះដឹង និងការអនុវត្តនៅមូលដ្ឋាន | C | M | H | AT, ET, F |
| | | ២.១.៥ | ធ្វើការកំណត់តម្លៃសេដ្ឋកិច្ច នៃធនធានតំបន់ដីមមោក | C, R | M | M | AT, ET, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការផ្នែកហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ៣. លើកកម្ពស់ចំណេះដឹង និងការកសាងសមត្ថភាព | ៣.១៖ លើកកម្ពស់ចំណេះដឹងសាធារណៈ ស្តីអំពីសារៈសំខាន់ នៃតំបន់ដីមមោក ភាពងាយរងគ្រោះរបស់ដីមមោកចំពោះអគ្គីភ័យ និងការគម្រាមកំហែងដោយសារផ្សែងអ័ព្ទ តាមរយៈការអនុវត្តផែនការទូលំទូលាយ | ៣.១.១ | ធ្វើការអភិវឌ្ឍ និងប្រើប្រាស់យុទ្ធសាស្ត្រទំនាក់ទំនង រួមមានការប្រើប្រាស់វីដេអូ ទូរទស្សន៍ សារព័ត៌មាន សាលារៀន សេវាកម្មផ្សព្វផ្សាយ សិក្ខាសាលា កម្មវិធី និងបណ្តាញផ្លាស់ប្តូរព័ត៌មាន ដូចជាបណ្តាញដីមមោកអាស៊ីអាគ្នេយ៍ | C, R | S | M | AT, ET, F |
| | | ៣.១.២ | ធ្វើការបង្កើត នូវសម្ភារៈ និងសកម្មភាព សម្រាប់លើកកម្ពស់ចំណេះដឹងជាភាសាមូលដ្ឋានឲ្យបានសមស្រប ដើម្បីធ្វើការ | C | S | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | លើកកម្ពស់ការយល់ដឹងអំពីតម្លៃ ការគម្រាមកំហែង ផលប៉ះពាល់ និងជម្រើសការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃតំបន់ដីមមោក | | | | |
| | | ៣.១.៣ | ផ្តល់ព័ត៌មានដល់សាធារណជន និងស្ថាប័នរដ្ឋាភិបាលនូវព័ត៌មានអំពីតួនាទីរបស់តំបន់ដីមមោកទាំងសារៈសំខាន់ផ្នែកអេកូឡូស៊ី និងសេដ្ឋកិច្ច | C,R | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៣.២៖ កសាងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធ នឹងការគ្រប់គ្រងតំបន់ដីមមោក | ៣.២.១ | ធ្វើការគាំទ្រនិងលើកកម្ពស់ធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន | C, R | C | H | AT, ET, F |
| | | ៣.២.២ | បង្កើតក្រុមអ្នកឯកទេសបង្គោលក្នុងការបណ្តុះបណ្តាលនិងក្រុមឯកទេសបង្គោលនៅមូលដ្ឋាន | C,R | M | M | AT, ET, F |
| | | ៣.២.៣ | បង្កើតយន្តការ និងរៀបចំកម្មវិធីបណ្តុះបណ្តាលសិក្ខាសាលា ទសន្សកិច្ចសិក្សា និងការកំសាន្តនានា | C, R | C | H | AT, F |
| | | ៣.២.៤ | គាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា សម្រាប់ការគ្រប់គ្រងតំបន់ដីមមោក រួមមានការបណ្តុះបណ្តាលជាក់ស្តែង | C,R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៣.២.២ | ការផ្តល់នូវសម្ភារៈ និងវត្ថុបណ្តុះបណ្តាលចាំបាច់ ដើម្បីសម្រួលដល់អាជ្ញាធរក្នុងតំបន់មានហានិភ័យចំពោះអគ្គីភ័យខ្លាំង | C | S | H | AT, ET, F |
| | | ៣.២.៦ | លើកកម្ពស់ការសម្របសម្រួល ក្នុងចំណោមអ្នកពាក់ព័ន្ធ ទាក់ទងនឹងការគ្រប់គ្រងតំបន់ដីមមោក តាមរយៈបណ្តាញ និងក្រុមការងារ | C | C | M | F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤. ការចែករំលែកព័ត៌មាន | ៤.១ លើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងជម្រុញការចែករំលែក | ៤.១.១ | បង្កើតឬពង្រឹងប្រព័ន្ធព័ត៌មានមានស្រាប់ ឬមិនទាន់មាន ដើម្បីធ្វើការគ្រប់គ្រង និងផលិតព័ត៌មានសមស្រប ពាក់ព័ន្ធនឹងតំបន់ដីមមោក | C, R | C | H | AT, ET, F |
| | | ៤.១.២ | ពង្រឹងការចែករំលែកបទពិសោធន៍ និងបណ្តាញថ្នាក់តំបន់ តាមរយៈការប្រើប្រាស់យន្តការ ដូចជាបណ្តាញសកម្មភាពផ្សេងអ័ព្ទអា ស៊ាន Online បណ្តាញតំបន់ដីមមោកអាស៊ីអាគ្នេយ៍បណ្តុំព័ត៌មានដីមមោក សិក្ខាសាលា ឯកសារ ក៏ដូចជាការពង្រឹងសមត្ថភាពថ្នាក់ជាតិ សម្រាប់ការចែករំលែកព័ត៌មាន | R | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤. ការចែករំលែកព័ត៌មាន | ៤.១ លើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងជម្រុញការចែករំលែក | ៤.១.៣ | លើកកម្ពស់ការចែករំលែកព័ត៌មាន ស្តីពីវិសាលភាពស្ថានភាព និងការគ្រប់គ្រងតំបន់ដីមមោក និងសៀវភៅឯកសារសម្រាប់ការអនុវត្តការគ្រប់គ្រងល្អបំផុត | C, R | C | H | AT, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ៥. គោលនយោបាយ និងបទដ្ឋានច្បាប់ | ៥.១៖ អភិវឌ្ឍ ឬពង្រឹងគោលនយោបាយ និងលិខិតបទដ្ឋានច្បាប់ ដើម្បីការពារ និងកាត់បន្ថយអគ្គីភ័យតំបន់ដីមមោក | ៥.១.១ | ធ្វើការតែងតាំងស្ថាប័នមួយជាក់លាក់ ក្នុងការគ្រប់គ្រងតំបន់ដីមមោក | C | S | H | AT, F |
| | | ៥.១.២ | ធ្វើការបង្កើត ឬធ្វើឲ្យមានបច្ចុប្បន្នភាពគោលនយោបាយ ឬយុទ្ធសាស្ត្រថ្នាក់ជាតិ ទាក់ទងនឹងការអភិរក្ស និងការប្រើប្រាស់ដោយឈ្លាសវៃ នៃតំបន់ដីមមោ ក រួមមានការសម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងតាមបែបសមាហរណកម្មតំបន់ដីមមោក | C | S | H | AT |
| | | ៥.១.៣ | ពង្រឹងការអនុវត្តច្បាប់ | C | M | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៦.១ ធ្វើការកាត់បន្ថយ និងរក្សា នូវកំរិតអប្បបរមា នៃការកើតឡើង នូវអគ្គីភ័យ និងផ្សែងអ័ព្ទ ដែលកើតមាន | ៦.១.១ | ធ្វើការកំណត់ នូវ តំបន់ដីមមោកក្នុងតំបន់ ដែលមានហានិភ័យអគ្គីភ័យខ្ពស់ ហើយធ្វើការបង្កើត និងលើកកម្ពស់វិធានការទប់ស្កាត់ | C, R | C | H | AT, ET, F |
| | | ៦.១.២ | ធ្វើការតាមដានលក្ខខណ្ឌអាកាសធាតុ និងចំណុច សំខាន់ ក្នុងតំបន់មានហានិភ័យខ្ពស់ និងធ្វើការប្រកាសភាពអាសន្នឲ្យបានត្រឹមត្រូវ | C, R | C | H | AT, ET, F |
| | | ៦.១.៣ | គ្រប់គ្រងកម្រិតទឹក ក្នុងតំបន់ដីមមោកឲ្យបានសមរម្យទៅតាមការប្រើប្រាស់ដីធ្លី ដើម្បីទប់ស្កាត់អគ្គីភ័យ | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៦.១.៤ | ធ្វើការបង្កើត និងលើកកម្ពស់បច្ចេកទេសសមស្របក្នុងការគ្រប់គ្រងតំបន់ដីមមោក | C, R | C | H | AT, ET, F |
| | | ៦.១.៥ | ពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័ន ក៏ដូចជាការពង្រឹងសមត្ថភាពរបស់ស្ថាប័នចូលរួម ក្នុងការទប់ស្កាត់និងគ្រប់គ្រងអគ្គីភ័យ ក្នុងតំបន់ដីមមោ ក រួមមានការបង្កើតឡើងនូវអង្គភាពទទួលខុសត្រូវក្នុងវិស័យព្រៃឈើ និងកសិកម្ម | C, R | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៦.១.៦ | លើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាជន និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានក្នុងការបង្ការ និងគ្រប់គ្រងអគ្គីភ័យ | CR | C | H | AT, F |
| | | ៦.១.៧ | អនុវត្ត នូវយុទ្ធសាស្ត្រមិនមានការដុត សម្រាប់រាល់ការធ្វើកសិកម្មទ្រង់ទ្រាយធំ និង មិនមានការដុត ឬដុតដោយមានការគ្រប់គ្រងសម្រាប់សហគមន៍មូលដ្ឋាន | C | C | H | AT, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ៧. ការអភិរក្សជីវចម្រុះតំបន់ដីមមោក | ៧.១៖ លើកកម្ពស់ការអភិរក្សជីវចម្រុះ | ៧.១.១ | ធ្វើការកំណត់តំបន់ដីមមោក ក្នុងតំបន់ដែលមានសារៈសំខាន់ សម្រាប់ការអភិរក្សជីវចម្រុះថ្នាក់តំបន់ឬថ្នាក់សាកល | C, R | C | H | AT, ET, F |
| | | ៧.១.២ | ធ្វើការវាយតម្លៃស្ថានភាពភាពខ្វះចន្លោះនិងកត្តាគម្រាមកំហែង ក្នុងបណ្តាញ នៃតំបន់ការពារ សម្រាប់តំបន់ដីមមោក និងជីវចម្រុះ និងធ្វើការកំណត់អាទិភាពសម្រាប់ការអភិរក្ស | C, R | C | H | AT, ET, F |
| | | ៧.១.៣ | ធ្វើការបង្កើតឡើង តាមផ្លូវច្បាប់ នូវតំបន់ដីមមោក ដែល | C, R | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | មានសារៈសំខាន់ថ្នាក់ជាតិ ថ្នាក់តំបន់ និង ថ្នាក់សាកល សម្រាប់ធ្វើជាតំបន់អភិរក្ស ឬការពារ | | | | |
| | | ៧.១.៤ | ពង្រឹងរាល់ទិដ្ឋភាពទាំងអស់ រួមមាន "ក្របខ័ណ្ឌស្ថាប័ន" សម្រាប់ការគ្រប់គ្រងតំបន់អភិរក្សតំបន់ដីមមោក | C | C | H | AT, ET, F |
| | | ៧.១.៥ | បង្កើតឡើង នូវយន្តការប្រើប្រាស់ប្រកបដោយនិរន្តភាព នៃតំបន់ដីមមោក សម្រាប់សហាគមន៍មូលដ្ឋាន ក្នុងតំបន់អភិរក្សតំបន់ដីមមោក | C | C | H | AT |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨. ការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហរណកម្ម | ៨.១៖ លើកកម្ពស់ការចូលរួមពីគ្រប់ស្ថាប័ន ក្នុងការគ្រប់គ្រងតំបន់ដីមមោក | ៨.១.១ | បង្កើតនូវអន្តរស្ថាប័នថ្នាក់ជាតិ ដើម្បីធ្វើការបង្កើត នូវយុទ្ធសាស្ត្រ សម្រាប់ការការពារ និងប្រើប្រាស់ប្រកបដោយនិរន្តរភាព នៃតំបន់ដីមមោក | C | S | H | មិនសមស្រប |
| | | ៨.១.២ | លើកទឹកចិត្តឲមានការគ្រប់គ្រងប្រកបដោយនិរន្តរភាព ដល់អ្នកប្រើប្រាស់តំបន់ដីមមោកទាំងអស់ រួមមានអ្នកពាក់ព័ន្ធមកពីវិស័យរុក្ខកម្ម កសិកម្ម និងចំការ | C | C | H | AT, F |

| | | | | | | |
|---|---|---|---|---|---|---|
| ៨.២៖ លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងតំបន់ដីមមោក ដោយប្រើប្រាស់វិធានគ្រប់គ្រងទូទាំងផ្ទៃអាង ហើយជៀសវាងភាពរាយប៉ាយ នៃតំបន់ដីមមោក | ៨.២.១ | បង្កើតឡើង នូវសារៈសំខាន់ជាមូលដ្ឋាន នៃរបបទឹកពីធម្មជាតិជាមូលដ្ឋានសម្រាប់ការអនុវត្តការគ្រប់គ្រងដ៏ល្អបំផុត | C | S | H | AT, ET, F |
| | ៨.២.២ | ធ្វើការគ្រប់គ្រង ឬដាក់កម្រិតការបង្ហូរ និងការបំលែងបន្ថែម (សម្រាប់វិស័យកសិកម្ម ចំការព្រៃឈើ លំនៅដ្ឋាន រ៉ែ ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ដទៃទៀត) នៃដីមមោក មានជម្រៅជ្រៅតំបន់ទួលដីមមោក តំបន់ដីមមោកមិនមានការរំខាន ក៏ដូចជាតំបន់នានា ដែលមិនទាន់មានការប្រកាស សម្រាប់សារៈសំខាន់នៃការអភិរក្ស | C | C | H | មិនសមស្រប |

| | | | | | | |
|---|---|---|---|---|---|---|
| | ៨.២.៣ | បង្កើត នូវគោលការណ៍ណែនាំ ក្នុងការជួយដល់ដំណើរការដាក់កម្រិតការប្រើប្រាស់ ឬបង្ហូរទឹកចេញពីដីមមោកមានជម្រៅជ្រៅ ទួលដីមមោក និងតំបន់ដីមមោកមិនទទួលរងការរំខាន | C | S | H | AT, ET, F |
| | ៨.២.៤ | បង្កើត នូវរបបការគ្រប់គ្រងទឹកសមរម្យមួយ សម្រាប់ទួលដីមមោក និងតំបន់ដីមមោ ក នៅជុំវិញរួមមានការបិទប្រឡាយមិនប្រើប្រាស់ និងប្រឡាយខុសច្បាប់ | C | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨. ការគ្រប់គ្រងតំបន់ដីមរោកតាមបែបសមាហារណកម្ម | ៨.៣ លើកកម្ពស់ការគ្រប់គ្រងតំបន់ដីមរោក និងព្រៃឈើតាមបែបសមា-ហារណកម្ម | ៨.៣.១ | ធានាឲ្យបាន នូវការគ្រប់គ្រង និងការពារ នៃព្រៃឈើ ក្នុងវាលភក់តំបន់ដីមរោកក្នុងតំបន់ការពារ និងចាត់វិធានការបន្ទាន់ក្នុងការការពារតំបន់ដីមរោកមិនទាន់មានការរំខាន ដែលនៅសេសសល់ | C, R | C | H | មិនសមស្រប |
| | | ៨.៣.២ | បង្កើតផែនការ និងគោលការណ៍ណែនាំ ក្នុងការគ្រប់គ្រងព្រៃបំរុង សម្រាប់ផលិតកម្ម | C | C | H | AT, F |
| | | ៨.៣.៣ | បង្កើត និងលើកកម្ពស់ការគ្រប់គ្រងព្រៃប្រកបដោយនិរន្តរភាព រួមមានការប្រមូលផលមានផលប៉ះពាល់តិចតួចការប្រមូលផលដោយមិនមានការបង្ហូរទឹក។ល។ | C | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៨.៣.៤ | បង្កើត និងអនុវត្តវិធានការស្តារឡើងវិញ ក្រោយពេលប្រមូលផល | C | C | H | AT, F |
| | | ៨.៣.៥ | ធ្វើការបង្កើត និងគ្រប់គ្រងតំបន់ការពារព្រៃដីមមោកតាមរយៈការគ្រប់គ្រងតាមបែបសមាហរណកម្ម | C | C | H | AT, F |
| | | ៨.៣.៦ | ធ្វើការគ្រប់គ្រងការប្រមូលផលខុសច្បាប់ និងសកម្មភាពពាណិជ្ជកម្ម ដែលពាក់ព័ន្ធ | C, R | C | H | AT, ET, F |
| | | ៨.៣.៧ | ប្រើប្រាស់តំបន់ដីមមោកសម្រាប់គោលបំណងផ្សេងត្រូវមានការគិតគូរ ដើម្បីទប់ស្កាត់ភាពរាយប៉ាយ | C | C | H | មិនសមស្រប |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៨.៣.៨ | ធ្វើការចងក្រងឯកសារជីវចម្រុះតំបន់ដីមមោក និងការប្រើប្រាស់ សម្រាប់សេដ្ឋកិច្ចសង្គម វប្បធម៌ និងអេកូឡូស៊ី | C, R | C | H | AT, F |
| | ៨.៤. គ្រប់គ្រងកសិកម្មក្នុងតំបន់ដីមមោក តាមបែបសមាហារណកម្ម | ៨.៤.១ | ធ្វើការដាក់កម្រិតចំពោះការអភិវឌ្ឍកសិកម្មលើដីមមោករាក់ៗ ដែលទទួលរងការខូចខាត | C | C | H | AT, F |
| | | ៨.៤.២ | ធ្វើការចងក្រងឯកសារ និងលើកកម្ពស់ចំណេះដឹង និងវិធីសាស្ត្រមូលដ្ឋាន ដូចជាវិធីសាស្ត្រទប់ស្កាត់ការបាក់ស្រុតដី និងការបង្ហូរទឹកលើសបរិមាណ និងការអនុវត្តការកាប់ឆ្ការដី និងការធ្វើកសិកម្មលើដី មមោកមានស្រាប់ដែលមានផលប៉ះពាល់ទាប | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ៨.៤.៣ | បង្កើតនូវបច្ចេកទេសការកាប់ដីល្អបំផុត ដែលអនុវត្តបាន និងសមស្រប សម្រាប់សហគមន៍រស់នៅជុំវិញតំបន់ដីមមោក | C | C | H | AT, ET, F |
| | | ៨.៤.៤ | លើកកម្ពស់ឲ្យមានការធ្វើកសិកម្ម ដែលមិនមានផ្សែងអ័ព្ទ តាមរយៈវិធានការ ការផ្តល់ធនធានលើកទឹកចិត្ត និងមិនមានធនធានលើកទឹកចិត្ត | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨. ការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហារណកម្ម | ៨.៥៖ លើកកម្ពស់ជីវភាពសហគមន៍ និងការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហារណកម្ម | ៨.៥.១ | លើកកម្ពស់ចំណេះដឹងសហគមន៍មូលដ្ឋាន ស្ដីពីតំបន់ដីមមោកតាមរយៈ: ការលើកកម្ពស់ចំណេះដឹង និងការអប់រំ | C, R | C | H | AT, F |
| | | ៨.៥.២ | គាំទ្រដល់ការការពារ និងការប្រើប្រាស់តំបន់ដីមមោកប្រកបដោយនិរន្តរភាពតាមរយៈការប្រើប្រាស់ច្បាប់ប្រពៃណី និងទំនៀមទំលាប់នៅមូលដ្ឋាន | C | C | H | AT, F |
| | | ៨.៥.៣ | ជម្រុញ និងលើកកម្ពស់ការលក់តាមទីផ្សារ នៃផលិតផលប្រពៃណី ដែលប្រមូលដោយសហគមន៍មូលដ្ឋានពីតំបន់ដីមមោក | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨. ការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហរណកម្ម | ៨.៥៖ លើកកម្ពស់ជីវភាពសហាគមន៍ និងការគ្រប់គ្រងតំបន់ដីមមោកតាមបែបសមាហរណកម្ម | ៨.៥.៤ | ធ្វើការគាំទ្រ និងផ្តល់អំណាចដល់សហាគមន៍មូលដ្ឋាន ក្នុងការការពារ និងប្រើប្រាស់ធនធានតំបន់ដីមមោកប្រកបដោយនិរន្តរភាព ក្នុងការចូលរួមដល់ជីវភាព និងសន្តិសុខបរិស្ថានរបស់ខ្លួន | C | C | H | AT, F |
| | | ៨.៥.៥ | ធ្វើការណែនាំគំនិត និងពង្រឹងជម្រើសជីវភាព ដើម្បីធានានូវកម្រិតអប្បបរមា នៃផលប៉ះពាល់ និងការពឹងផ្អែកលើតំបន់ដីមមោក | C, R | C | H | AT, ET, F |
| | | ៨.៥.៦ | ជម្រុញឲអ្នកពាក់ព័ន្ធនៅមូលដ្ឋានចូលរួមក្នុងការគ្រប់គ្រងតំបន់ដីមមោក | C | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩. ការបង្កើតឡើង និងការលើកកម្ពស់ទីតាំងគម្រូ | ៩.១. លើកកម្ពស់ការអនុវត្តការគ្រប់គ្រងល្អបំផុត | ៩.១.១ | ធ្វើការកំណត់ និងលើកកម្ពស់ការបង្កើតទីតាំងគម្រូ សម្រាប់ការអនុវត្តការគ្រប់គ្រងល្អបំផុត។ ឧទាហរណ៍ ទីតាំងសម្រាប់ទេសចរណ៍ធម្មជាតិ ជម្រើសជីវភាព និងការស្តារឡើងវិញ។ល។ | C, R | C | H | AT, ET, F |
| | | ៩.១.២ | បង្កើត នូវគម្រោងសាកល្បងក្នុងប្រទេសនីមួយៗ (យោងតាមតម្រូវការមូលដ្ឋាន) ដើម្បីធ្វើការសាកល្បងវិធានទប់ស្កាត់អគ្គីភ័យ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពថ្មីនៃតំបន់ដីមមោក | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩. ការបង្កើតឡើង និងការលើកកម្ពស់ទីតាំងគម្រូ សម្រាប់ ការគ្រប់គ្រងតំបន់ដីមមោក | ៩.១. លើកកម្ពស់ការអនុវត្តការគ្រប់គ្រងល្អបំផុត | ៩.១.៣ | ជម្រុញឲមានការអនុវត្តការគ្រប់គ្រងតំបន់ដីមមោកល្អបំផុតតាមរយៈការស្រាវជ្រាវ និង ការអភិវឌ្ឍ | C, R | C | H | AT, ET, F |
| | | ៩.១.៤ | បង្កើតក្រុមការងារបច្ចេកទេសថ្នាក់ជាតិចម្រុះ ដើម្បីដោះស្រាយបញ្ហាក្តីបារម្ភទូទៅ ដូចជាការគ្រប់គ្រងទឹកតំបន់ដមមោក ការធ្វើវនប្បកម្ម ឬជម្រើសការស្តារឡើងវិញ | C, R | C | H | AT, ET, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ១០. ការស្ដាបនា និងការស្ដារឡើងវិញ | ១០.១៖ បង្កើត នូវបច្ចេកទេសសមស្រប សម្រាប់ការស្ដាបនា និងស្ដារឡើងវិញ នៃតំបន់ដីមមោក ទទួលរងការខូចខាត | ១០.១.១ | បង្កើតឡើង និងលើកកម្ពស់គោលការណ៍ណែនាំ និងសៀវភៅណែនាំ ឲ្យបានទូលំទូលាយ ស្ដីពីការស្ដាបនា និងស្ដារឡើងវិញ នៃតំបន់ដីមមោក ដោយប្រើប្រាស់ចំណេះដឹងមូលដ្ឋាន បទពិសោធន៍ថ្នាក់តំបន់ និងគំហើញពីការស្រាវជ្រាវ និងការអភិវឌ្ឍ | C, R | C | H | មិនសមស្រប |
| | | ១០.១.២ | បង្កើត នូវគម្រោងសាកល្បង ដើម្បីធ្វើការសាកល្បងបច្ចេកទេស | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០. ការស្តារបនា និងការស្តារឡើងវិញ | ១០.១៖ បង្កើត នូវបច្ចេកទេសសមស្រប សម្រាប់ការស្តាបនា និងស្តារឡើងវិញ នៃតំបន់ដីមមោកទទួលរងការខូចខាត | ១០.១.៣ | រៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលជាក់លាក់ ស្តីអំពីការស្តាបនា និងការស្តារឡើងវិញ នៃតំបន់ដីមមោក | C, R | C | H | AT, ET, F |
| | | ១០.១.៤ | ធ្វើការពិនិត្យឡើងវិញ និងធ្វើឲ្យមានបច្ចុប្បន្នភាពគោលការណ៍ណែនាំដោយផ្អែកលើបទពិសោធន៍ និងចំណេះដឹងមូលដ្ឋាន និងគំហើញពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១០.២៖ ស្តារតំបន់ដីមមោកដែលទទួលអគ្គីភ័យ ការបង្ហូរទឹកចេញ និងទទួលរងការខូចខាត | ១០.២.១ | ធ្វើការកំណត់ និងបែងចែកតំបន់ដីមមោកទទួលរងការខូចខាតផ្អែកលើជម្រើសការស្តារ តាមចំណេះដឹងមូលដ្ឋាន បទពិសោធន៍ថ្នាក់តំបន់ គំហើញមកពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបច្ចេកវិទ្យាសមស្រប | C, R | C | H | AT, ET, F |
| | | ១០.២.២ | បង្កើត នូវកម្មវិធីថ្នាក់ជាតិ ដើម្បីផ្តួចផ្តើមសកម្មភាពស្តារ និងស្តាបនាឡើងវិញ | C, R | C | H | AT, ET, F |
| | | ១០.២.៣ | អនុវត្តកម្មវិធី សម្រាប់ការស្តារតំបន់ដីមមោកឡើងវិញ | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១. តំបន់ដីមមោក និងការប្រែប្រួលអាកាសធាតុ | ១១.១៖ ការពារ និង លើកកម្ពស់មុខងារ តំបន់ដីមមោក សម្រាប់ការស្រូប និង ស្តុកកាបោន | ១១.១.១ | ធ្វើការគណនាបរិមាណសមាស ធាតុកាបោនក្រោមដី និងលើដី ក្នុងតំបន់ដីមមោក ក្នុងប្រទេស អាស៊ាន និងតួនាទីរបស់តំបន់ដី មមោកក្នុងការកាត់បន្ថយការប្រែ ប្រួលអាកាសធាតុ | C | C | H | AT, ET, F |
| | | ១១.១.១ | ធ្វើការកំណត់ នូវតំបន់ដីមមោក ទទួលរងការខូចខាត និងរិះរក ឱកាសក្នុងការស្តារ តាមរយៈ យន្តការអភិវឌ្ឍន៍ស្អាត (CDM) ក្រោមក្យូតូប្រូតូកូល | C | C | H | AT, ET, F |
| | | ១១.១.៣ | ធ្វើការសម្របសម្រួលឲមានការគាំ ទ្រ សម្រាប់ការគ្រប់គ្រង និងស្តារ តំបន់ដីមមោក ពីយន្តការផ្តល់មូល និធិពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុ។ | C | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១. តំបន់ដីមមោក និងការប្រែប្រួលអាកាសធាតុ | ១១.១៖ ការពារ និងលើកកម្ពស់មុខងារតំបន់ដីមមោកសម្រាប់ការស្រូប និងស្តុកកាបោន | ១១.១.៤ | ធ្វើការវាយតម្លៃផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមានឡើងដោយសារការប្រើប្រាស់ដីមមោកជាប្រភពថាមពល | C | C | H | AT, ET, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ១១. តំបន់ដីមមោក និងការប្រែប្រួលអាកាសធាតុ | ១១.១៖ ធ្វើការគាំទ្រដល់ដំណើការបន្សាំរបស់តំបន់ដីមមោកទៅនឹងការប្រែប្រួលអាកាសធាតុ | ១១.២.១ | ធ្វើការវាយតម្លៃផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុលើប្រព័ន្ធអេកូឡូស៊ីតំបន់ដីមមោកក្នុងប្រទេសអាស៊ាន | C, R | C | H | AT, ET, F |
| | | ១១.២.២ | ធ្វើការកំណត់ នូវយុទ្ធសាស្ត្រគ្រប់គ្រង ដែលសមស្រប ក្នុងការធានានូវកម្រិតអប្បបរមា នៃភាពងាយរងគ្រោះរបស់តំបន់ដីមមោកចំពោះការប្រែប្រួលអាកាសធាតុលើពិភពលោក | C, R | C | H | AT, ET, F |
| | | ១១.២.៣ | ធ្វើសមាហរណកម្មបញ្ហា | C, R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | តំបន់ដីមមោកទៅក្នុងផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ និងថ្នាក់តំបន់ | | | | |
| | | ១១.២.៤ | ស្វែងរកប្រភពឧបត្ថម្ភគាំទ្រ សម្រាប់ការគ្រប់គ្រងតំបន់ដីមមោកពីមូលនិធិការបន្សាំ ដោយភ្ជាប់ទៅនឹងសន្ធិសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) | C, R | L | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ | ១២.១៖ លើកកម្ពស់ការផ្លាស់ប្ដូរឯកទេសក្នុងការដោះស្រាយបញ្ហាគ្រប់គ្រងតំបន់ដីមមោក | ១២.១.១ | អភិវឌ្ឍគម្រោងស្រាវជ្រាវសហប្រតិបត្តិការថ្នាក់តំបន់ និងសកម្មភាពផ្សេងៗទៀត ដែលមានការចូលរួមពីអ្នកឯកទេសតាមបណ្ដាប្រទេសអាស៊ាន | R | C | H | AT, ET, F |
| | | ១២.១.២ | ពង្រឹងបណ្ដាញដីមមោកអាស៊ីអាគ្នេយ៍ ដោយបញ្ចូលអ្នកឯកទេសទាំងអស់ ពាក់ព័ន្ធតំបន់ដីមមោក ក្នុងតំបន់អាស៊ីអាគ្នេយ៍ | R | C | H | AT, F |
| | | ១២.១.៣ | រៀបចំសិក្ខាសាលាថ្នាក់តំបន់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្ដូរបទពិសោធន៍ | R | C | M | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១២.២៖ ការបង្កើតឡើង នូវ "មជ្ឈមណ្ឌលមានឧត្តមភាព" ក្នុងតំបន់សម្រាប់ធ្វើការវាយតម្លៃ និងគ្រប់គ្រងតំបន់ដីមមោក | ១២.២.១ | ធ្វើការតែងតាំង "មជ្ឈមណ្ឌលមានឧត្តមភាព" ក្នុងតំបន់ ធ្វើការលើការងារជាក់លាក់ណាមួយ ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោក | C, R | S | H | AT, ET, F |
| | | ១២.២.២ | ធ្វើការគាំទ្រដល់សកម្មភាព ដែលបានជ្រើសរើស និងកំពុងពង្រឹងរបស់មជ្ឈមណ្ឌលបានជ្រើសរើស | R | L | M | AT, ET, F |
| | | ១២.២.៣ | ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌល | R | C | M | AT, ET, F |
| | | ១២.២.៤ | បញ្ចូលបញ្ហាដីមមោកទៅក្នុងក្របខ័ណ្ឌអាស៊ាន | R | M | M | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ពាក់ព័ន្ធនឹងការអភិរក្សធម្មជាតិ និងជីវចម្រុះ កិច្ចព្រមព្រៀងបរិស្ថានពហុភាគី ការគ្រប់គ្រងធនធានទឹក វិស័យរុក្ខកម្ម និងវិស័យកសិកម្ម និងវិស័យអប់រំ | | | | |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

| គោលដៅប្រតិបត្តិ | | សកម្មភាព | | កម្រិតសកម្មភាពបានស្នើឡើង | រយៈពេល | អាទិភាព | តម្រូវការឧបត្ថម្ភគាំទ្រ |
|---|---|---|---|---|---|---|---|
| ១២. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ | ១២.៣៖ ចូលរួមចំណែកដល់ការអនុវត្តយន្តការកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ព័ន្ធ | ១២.៣.២ | ធានានូវការចូលរួមចំណែកនៃយុទ្ធសាស្ត្រថ្នាក់តំបន់ចំពោះការអនុវត្ត កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន | R | C | H | មិនសមស្រប |
| | | ១២.៣.៣ | ធ្វើការឧបត្ថម្ភគាំទ្រផ្នែកធនធាន ស្តីពីតំបន់ដីមោកពាក់ព័ន្ធនឹងសន្ធិសញ្ញាអន្តរជាតិ (រួមមានសន្ធិសញ្ញារ៉ាំសារ សន្ធិសញ្ញា ស្តីពីជីវចម្រុះ សន្ធិសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងនឹងភាពរហោដ្ឋាន និងសន្ធិសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ) | R | C | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១២.៤៖ លើកកម្ពស់ភាពជាដៃគូ រវាងអ្នកពាក់ព័ន្ធចម្រុះ ដើម្បីគាំទ្រដល់ការគ្រប់គ្រងតំបន់ដីមមោក | ១២.៤.១ | ពង្រឹងភាពជាដៃគូ ក្នុងចំណោមអ្នកពាក់ព័ន្ធតាមរយៈ APMI និងការងារពាក់ព័ន្ធ | R | C | H | AT, ET, F |
| | | ១២.៤.២ | ជម្រុញ ឬពង្រឹងភាពជាដៃគូនៅមូលដ្ឋាន និងថ្នាក់ជាតិក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ រួមមានស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងវិស័យឯកជន ដើម្បីធ្វើការអនុវត្តការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ដីមមោកប្រកបដោយប្រសិទ្ធភាព | C | C | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣. ផ្ដល់ហិរញ្ញប្បទាន សម្រាប់ទំនើបកម្ម | ១៣.១៖ គៀងគរធនធានហិរញ្ញវត្ថុ សម្រាប់កម្មវិធី និងសកម្មភាព ដើម្បី សម្រេចឲ្យបាននូវ គោលដៅរបស់យុទ្ធសាស្រ្ត | ១៣.១.១ | បង្កើត នូវយុទ្ធសាស្រ្តហិរញ្ញវត្ថុ សម្រាប់ការអនុវត្ត APMS រួមមានការវិភាគការខាតបង់-អត្ថប្រយោជន៍ | C, R | S | H | AT, ET, F |
| | | ១៣.១.២ | អនុវត្តការសិក្សាភាពអាចធ្វើបាន ដើម្បីរិះរកគ្រោងការអ្នកប្រើប្រាស់ជាអ្នកបង់ប្រាក់ និងអ្នកបំពុលជាអ្នកបង់ប្រាក់ ការលើកទឹកចិត្តដល់ការបង់ពន្ធ ឬជម្រើសផ្សេងៗ ដើម្បីគៀងគរធនធានប្រកបដោយនិរន្តរភាព ដើម្បីធ្វើការគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្ត | C, R | S | H | AT, ET, F |
| | | ១៣.១.៣ | បង្កើត ឬលើកកម្ពស់យន្តការមូលនិធិ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្ត | C, R | S | H | AT, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣. ផ្តល់ហិរញ្ញទាន សម្រាប់ពង្រឹងបន្ថែម | ១៣.១៖ គៀងគរធនធាន ហិរញ្ញវត្ថុ សម្រាប់កម្មវិធី និងសកម្មភាព ដើម្បី សម្រេចឲ្យបាននូវ គោលដៅរបស់ យុទ្ធសាស្ត្រ | ១៣.១.៤ | រៀបចំថវិកា និងសំណើជាក់លាក់ សម្រាប់ផ្តល់មូលនិធិ ដល់សកម្មភាព រដ្ឋាភិបាលថ្នាក់ជាតិ អ្នកគាំទ្រពីខាងក្រៅ និងប្រភពផ្សេងៗ ដើម្បីគៀងគរធនធាន សម្រាប់គាំទ្រ ដល់ការអនុវត្តយុទ្ធសាស្ត្រ | C, R | C | H | AT, ET, F |
| | | ១៣.១.៥ | រៀបចំវេទិកាទៀងទាត់មួយ រវាងម្ចាស់ជំនួយ និងអ្នកគាំទ្រ ដើម្បីធ្វើការសម្របសម្រួល នូវសកម្មភាពមូលនិធិ ដែលបានសម្របសម្រួល | C, R | C | H | AT, ET, F |
| | | ១៣.១.៦ | បង្កើត នូវយន្តការផ្តល់មូលនិធិ ពាក់ព័ន្ធនឹងការបង់ប្រាក់ សម្រាប់សេវាកម្មបរិស្ថាន តំបន់ដីមហោក ដើម្បីគៀងគរ មូលនិធិ សម្រាប់ការអភិរក្ស | C, R | S | H | AT, ET, F |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | និងគ្រប់គ្រងតំបន់ដីមមោក | | | | |
| | | ១៣.១.៧ | បង្កើតនូវយន្តការសមស្រប ដើម្បីបញ្ចូលធនធានដល់រដ្ឋាភិបាល ឬសហាគមន៍ ដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងសកម្មភាពស្តារ (ដូចជាឥណទានខ្នាតតូច) | C | S | H | AT, ET, F |

** AT: បច្ចេកទេសរបស់អាស៊ាន, ET: បច្ចេកទេសមកពីប្រភពខាងក្រៅ និង F: តម្រូវការហិរញ្ញវត្ថុ

# 3 យន្តការអនុវត្តន៍

## 3.1 យន្តការអនុវត្តថ្នាក់តំបន់

យន្តការអនុវត្តយុទ្ធសាស្ត្រនឹងធ្វើការងារបន្ថែម លើដំណើរការនាពេលបច្ចុប្បន្នរបស់ APMI។ យន្តការសំខាន់ៗ សម្រាប់ការគ្រប់គ្រងនឹងធ្វើឡើងតាមរយៈយន្តការ របស់អាស៊ាន ពាក់ព័ន្ធនឹងអគ្គីភ័យលើដី និងអគ្គីភ័យក្នុងព្រៃ និងការបំពុលផ្សែងអ័ព្ទឆ្លងដែន ជាពិសេសគឺ ASOEN-HTTF។ AMMH និង ASOEN-HTTF អាចមានការបញ្ចូលទៅក្នុងផ្នែកផ្សេងៗ បើពិនិត្យមើលលើការបង្កើតឡើង នូវយន្តការ ក្រោមកិច្ចព្រមព្រៀងអាស៊ានស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន។ គម្រោង នៃយន្តការមានបង្ហាញជូនក្នុងដ្យាក្រាមខាងក្រោម:



ដ្យាក្រាម ១៖ ដ្យាក្រាមលំហូរបង្ហាញពីរចនាសម្ព័ន្ធ របស់ APMI ដែលធ្វើឡើង សម្រាប់ជាមគ្គុទ្ទេសន៍ និងការអនុវត្តឲ្យជោគជ័យលើយុទ្ធសាស្រ្តថ្នាក់តំបន់។

**ឧត្តមមន្ត្រីអាស៊ាន សម្រាប់ក្រុមការងារបច្ចេកទេសផ្សេងអំពូអាស៊ាន (ASOEN-HTTF)**

ASOEN-HTTF នឹងផ្តល់គោលគំនិត និងការ ណែនាំផ្លូវផ្នែកគោលនយោបាយ សម្រាប់ការអនុវត្តយុទ្ធសាស្រ្ត ក៏ដូចជាការសម្របសម្រួល និងការ ទំនាក់ទំនងសកម្មភាព ការងារនៅថ្នាក់ជាតិ។ ឯកសារក៏បានបញ្ជាក់ផងដែរថា ក្រុមអ្នកឯកទេសបន្ថែម ស្តីពីតំបន់ដីមមោកនឹងត្រូវបង្កើតឡើង ក្រោម ASOEN-HTTF ដើម្បីធ្វើការពិនិត្យឲ្យបានជាក់លាក់ លើបញ្ហាតំបន់ដីមមោក និងផ្តល់ នូវធនធានដល់ការអនុវត្តយុទ្ធសាស្រ្ត និងអនុវត្តការងារ បច្ចេកទេសផ្សេងៗ។ ទំនាក់ទំនងក៏អាចបង្កើតឡើងផងដែរ ទៅក្នុងរចនាសម្ព័ន្ធរបស់ អាស៊ានផ្សេងទៀត ដែលសមស្រប ជាពិសេសក្រុមការងារអាស៊ាន ស្តីការអភិរក្សធម្មជាតិ និងជីវចម្រុះ។

**លេខាធិការអាស៊ាន**

លេខាធិការអាស៊ាននឹងទទួលខុសត្រូវក្នុងការសម្របសម្រួលជាផ្លូវការរវាងប្រទេស ជាសមាជិកអាស៊ាន និងសម្របសម្រួលសកម្មភាព និងកិច្ចប្រជុំថ្នាក់តំបន់សំខាន់ៗ ក៏ដូចជាទំនាក់ទំនងការងារផ្សេងៗទៀត ដែលបានសម្របសម្រួល តាមរយៈលេខាធិការ អាស៊ាន។

**មជ្ឈមណ្ឌលបរិស្ថានពិភពលោក(GEC)**

GEC ជាអង្គការមួយមានការបង្កើតឡើងបានយ៉ាងល្អ ក្នុងតំបន់អាស៊ាន ដោយមាន ឯកទេសពិសេសលើតំបន់ដីមមោក និងមានអ្នកសម្របសម្រួលបណ្តាញដីមមោកអាស៊ី អាគ្នេយ៍ ដែលមានសមាជិកលើសពី ៥០០នាក់។ អង្គការនេះគឺជាដៃគូស្ថាបនិករបស់ APMI ហើយបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងប្រតិបត្តិការដល់ APMI ចាប់តាំងពី

ចាប់ផ្ដើមមកម្ល៉េះ។ GEC ក៏បានបញ្ជាក់ថានឹងបន្តការគាំទ្រផ្នែកបច្ចេកទេសនិងប្រតិបត្តិការ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ ក៏ដូចជាជួយក្នុងការគៀងគរធនធាន សម្រាប់គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ។

**ក្រុមអ្នកឯកទេសបច្ចេកទេស (ក្រុមប្រឹក្សាបច្ចេកទេស)**

អ្នកឯកទេសពិភពលោកល្បីៗ ខាងតំបន់ដីមមោកតំបន់ត្រូពិកនឹងត្រូវបង្កើតឡើង សម្រាប់ជាគោលបំណងជាមគ្គុទ្ទេសន៍ ឬបង្ហាញទិសដៅ ក្រុមអ្នកឯកទេសបច្ចេកទេស ឬក្រុមទីប្រឹក្សាបច្ចេកទេស (TEG/TAG)។ គោលបំណងចំបងរបស់ក្រុមការងារនេះ គឺត្រូវដើរតួនាទី ក្នុងការដឹកនាំផ្លូវ ធ្វើការពិនិត្យឡើងវិញ និងផ្ដល់ដំបូន្មាន ពាក់ព័ន្ធនឹង បច្ចុប្បន្នភាព នៃវិធីសាស្ត្រគ្រប់គ្រងតំបន់ដីមមោកប្រកបដោយនិរន្តរភាព។

**ប្រទេសសមាជិកអាស៊ាន (AMCs)**

ប្រទេសសមាជិកអាស៊ាននឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តយុទ្ធសាស្ត្រ ដោយផ្ទាល់ ក្នុងប្រទេសនីមួយៗ ក៏ដូចជាការចូលរួមចំណែកដល់ការងារថ្នាក់តំបន់។ ការអនុវត្តការងារ របស់ប្រទេសសមាជិកអាស៊ាននឹងត្រូវអនុវត្តតាមផែនការសកម្មភាពថ្នាក់ជាតិរបស់ខ្លួន។

**ដៃគូ**

ដៃគូនៃគំនិតផ្តួចផ្តើមនេះ រួមមានអង្គការ ឬគម្រោងកំពុងបន្ត ដែលកំពុងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីមមោកដោយមាននិរន្តរភាពក្នុងតំបន់។ ដៃគូទាំងនេះ ចូលរួមចំណែកតាមរយៈ៖

- អញ្ជើញឲ្យមានការចូលរួមពីសំណាក់ប្រទេស និងស្ថាប័ន ក្នុងតំបន់អាស៊ាន លើសកម្មភាពការងារណាមួយសមស្រប
- ផ្ដល់ការចូលរួមផ្សេងៗ ដែលសមស្រប

### អ្នកគាំទ្រ

អ្នកគាំទ្រ រួមមានម្ចាស់ជំនួយ អ្នកស្រាវជ្រាវ ឬ ស្ថាប័នអប់រំ វិស័យឯកជន និងសារព័ត៌មាន។ អ្នកទាំងនេះជួយតាមរយៈ៖

- ផ្តល់ នូវមូលនិធិ ឬការដឹកនាំផ្លូវផ្នែកបច្ចេកទេស
- លើកកម្ពស់គំនិតផ្តួចផ្តើម និងផ្តល់ នូវការឧបត្ថម្ភគាំទ្រផ្សេងៗ

ការចូលរួមដ៏សកម្មរបស់ដៃគូ និងអ្នកគាំទ្រ ក្នុងការអនុវត្តយុទ្ធសាស្ត្រនឹងធ្វើឡើងតាមរយៈការប្រើប្រាស់ឯកទេស និងបទពិសោធន៍របស់អ្នកទាំងនោះ ហើយនិងធ្វើការជម្រុញឲ្យមានស្មារតីប្តេជ្ញាចិត្ត និងមានភាពម្ចាស់ការលើគម្រោង និងសកម្មភាពផ្សេងៗ។

## 3.2 យន្តការអនុវត្តថ្នាក់ប្រទេស

នៅថ្នាក់ជាតិ ការសម្របសម្រួលសកម្មភាពការងារ គឺបានបញ្ជាក់យ៉ាងច្បាស់ថាត្រូវធ្វើឡើងតាមរយៈយន្តការសមស្រប ដែលបានបង្កើតឡើង សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពថ្នាក់ជាតិ ដែលពាក់ព័ន្ធ។ ចំណុចលំអិតជាក់លាក់ របស់យន្តការមានភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយមានការណែនាំផ្លូវដោយផែនការសកម្មភាពថ្នាក់ជាតិរៀងៗខ្លួន។ យន្តការត្រូវបានរំពឹងថានឹងរៀបចំឡើងដោយផ្អែកលើគម្រូខាងក្រោម៖




ដ្យាក្រាម ២៖ ដ្យាក្រាមលំហូរបង្ហាញពីយន្តការ ដែលបានស្នើឡើង សម្រាប់ការអនុវត្តយន្តការថ្នាក់ជាតិ

## ជនបង្គោល

ជនបង្គោល នៃក្រុមការងារនេះ នឹងដើរតួនាទីជាជនបង្គោល របស់ក្រុមការងារបច្ចេកទេសផ្សេងអ័ព្ទ។ ជនបង្គោលត្រូវធ្វើជាមន្ត្រីទំនាក់ទំនង សម្រាប់ការអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិ ហើយត្រូវបានរំពឹងទុកថាត្រូវៈ

- ផ្តល់ទិសដៅដល់ក្រុមការងារ

- ពិនិត្យមើលការអភិវឌ្ឍរបស់ផែនការសកម្មភាពថ្នាក់ជាតិ
- បែងចែកតួនាទី និងការទទួលខុសត្រូវដល់ស្ថាប័នពាក់ព័ន្ធផ្សេងៗ

## មន្ត្រីការិយាល័យ

មន្ត្រីការិយាល័យ ប្រហែលជាមានការតែងតាំងក្នុងស្ថាប័នជនបង្គោល ឬភ្នាក់ងារផ្សេងៗទៀត ដើម្បីជួយដល់ជនបង្គោល។ តួនាទីរបស់មន្ត្រីការិយាល័យគឺត្រូវៈ

- ធ្វើការសម្របសម្រួលការងារ សម្រាប់ការធ្វើផែនការ និងការអនុវត្ត
- ធានាថាព័ត៌មានបានផ្តល់ដល់ស្ថាប័នពាក់ព័ន្ធ
- ធានាថាព័ត៌មានជាមូលដ្ឋានត្រូវបានផ្តល់ដល់អ្នកពាក់ព័ន្ធសំខាន់ៗ
- ធ្វើការរៀបចំកិច្ចប្រជុំ និងសម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ាន និងដៃគូផ្សេងទៀត

## ក្រុមការងារថ្នាក់ជាតិ (បណ្តោះអាសន្ន ឬអចិន្ត្រៃយ៍)

សមាជិកគួរតែជាអ្នកពាក់ព័ន្ធផ្នែកបច្ចេកទេសសំខាន់ៗ (រួមមានស្ថាប័នរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន) ដែលសមស្រប។ តួនាទីរបស់ក្រុមការងារនេះគឺត្រូវៈ

- ផ្តល់យោបល់បច្ចេកទេសដល់ជនបង្គោល
- បង្កើត នូវគោលការណ៍ណែនាំបច្ចេកទេស
- ផ្តល់អនុសាសន៍ និងយោបល់ សម្រាប់វិធានការ

## គណៈកម្មាធិការសម្របសម្រួល

គណៈកម្មាធិការសម្របសម្រួលរួមមានស្ថាប័នតាក់តែងច្បាប់ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានជ្រើសរើស។ តួនាទីរបស់គណៈកម្មាធិការគឺត្រូវៈ

- តម្រង់ទិសដៅដល់ជនបង្គោល ឬក្រុមការងារ

- ពិនិត្យមើលលើការអភិវឌ្ឍ នៃផែនការសកម្មភាពថ្នាក់ជាតិ
- បែងចែកតួនាទី និងការទទួលខុសត្រូវដល់ស្ថាប័នពាក់ព័ន្ធផ្សេងៗ
- ធ្វើការពិចារណា និងអនុម័តលើផែនការសកម្មភាពថ្នាក់ជាតិ

**ដៃគូ និងអ្នកគាំទ្រ**

ដៃគូ និងអ្នកគាំទ្រអាចជួយដល់ការបង្កើត និងអនុវត្តសកម្មភាពការងារ

## 3.3 ការប្រើប្រាស់ធនធាន

យុទ្ធសាស្ត្រប្រើប្រាស់ធនធាន សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ នឹងត្រូវធ្វើការអភិវឌ្ឍបន្ថែមនៅឆ្នាំទី ១ នៃការអនុវត្ត (មើលសកម្មភាព ១៣.១.១ ក្នុងតារាង ២)។ យ៉ាង ហោចណាស់ ក៏មានប្រភពផ្តល់មូលនិធិ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចំនួន ៣ ធំៗ។ ប្រភពទាំងនេះ រួមមានការចូលរួមចំណែកដោយផ្ទាល់ពីគ្រប់ប្រទេសសមាជិកអាស៊ាន ឬប្រទេសមួយចំនួនចំពោះសកម្មភាពជាក់លាក់ ធនធានរួមរបស់អាស៊ាន និងប្រភពមូលនិធិខាងក្រៅ។ ប្រទេសអាស៊ាននឹងធ្វើការអនុម័ត នូវវិធានចម្រុះទាំងនេះ ក្នុងការប្រើប្រាស់ធនធាន ដើម្បីឲ្យធនធាន ក្នុងប្រទេសអាស៊ាន និងមូលនិធិខាងក្រៅអាចបំពេញឲ្យគ្នាទៅវិញទៅមក។

មានការរំពឹងទុកថា ប្រទេសជាសមាជិកអាស៊ានត្រូវបែកចែកធនធានគ្រប់គ្រាន់ក្នុងការគាំទ្រ និងអនុវត្តយុទ្ធសាស្ត្រថ្នាក់តំបន់ និងថ្នាក់ជាតិ។ អាស្រ័យហេតុនេះ ប្រទេសសមាជិកអាស៊ានគួរបញ្ជ្រាតយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ដីមមោកអាស៊ាន និងជាពិសេសផែនការសកម្មភាពថ្នាក់ជាតិទៅក្នុងកម្មវិធីអភិវឌ្ឍថ្នាក់ជាតិ។ ក្នុងន័យនេះ ការបែងចែកមូលនិធិថ្នាក់ជាតិ ក្នុងការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ដីមមោ កអាស៊ាន ហើយជាពិសេសមូលនិធិ សម្រាប់ផែនការសកម្មភាពថ្នាក់ជាតិ អាចគៀងគរបានយ៉ាងស្រួល។

យន្តការមូលនិធិនឹងអាចត្រូវបានបង្កើតឡើង ហើយមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីប្រើប្រាស់ជាប្រភពអាចទុកចិត្ត និងពឹងផ្អែកបាន ក្នុងការសម្របសម្រួលការអនុវត្ត

យុទ្ធសាស្រ្ត (មើលសកម្មភាព ១៣.១.៣ ក្នុងតារាង ២)។ យន្តការមូលនិធិទាំងនេះ អាចមានទម្រង់ជាធនធានរួម នៃធនធានហិរញ្ញវត្ថុ ដែលត្រូវធ្វើឡើងពីការចូលរួម របស់ប្រទេសសមាជិកអាស៊ាន ដោយផ្អែកលើគ្រោងការមួយទទួលយកបានទៅវិញទៅមក។

ការចូលរួមពីដៃគូពិភាក្សារបស់អាស៊ាន និងស្ថាប័នម្ចាស់ជំនួយផ្សេងៗ នៅតែជាប្រភពធនធានដ៏សំខាន់ សម្រាប់យុទ្ធសាស្រ្ត។ ទន្ទឹមនឹងនោះក៏មាន ប្រភព នៃការផ្តល់មូលនិធិបន្ថែមមួយទៀតគឺវិស័យឯកជន។

វេទិកាទៀងទាត់វរវាងម្ចាស់ជំនួយ និងអ្នកគាំទ្រ នឹងត្រូវរៀបចំឡើង ដើម្បីគៀងគរមូលនិធិមកពីខាងក្រៅ និងធ្វើការសម្របសម្រួលមូលនិធិសកម្មភាពការងារ ដែលត្រូវមានការសម្របសម្រួល (មើលសកម្មភាពចំណុច ១៣.១.៥)។ ថវិកា និងសំណើជាក់លាក់សម្រាប់ផ្តល់មូលនិធិដល់សកម្មភាពការងារ ដោយរដ្ឋាភិបាលថ្នាក់ជាតិ អ្នកគាំទ្រពីខាងក្រៅ និងប្រភពផ្សេងៗទៀតនឹងត្រូវធ្វើឡើង ដើម្បីធ្វើការគៀងគរធនធាន សម្រាប់គាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្ត (មើលចំណុចសកម្មភាព ១៣.១.៤)។

ទន្ទឹមនឹងគ្នានេះដែរ យុទ្ធសាស្រ្តនឹងធ្វើការរិះរក និងបង្កើតឡើង នូវ យន្តការ និងជម្រើស ក្នុងការគៀងគរធនធានប្រកបដោយនិរន្តរភាព សម្រាប់ការអភិរក្ស និងគ្រប់គ្រងតំបន់ដីមមោក (មើលសកម្មភាព ១៣.១.២, ១៣.១.៦ និង ១៣.១.៧)។

## 3.4 យន្តការតាមដាន និងវាយតម្លៃ

យន្តការតាមដាន និងវាយតម្លៃនឹងត្រូវបង្កើតឡើងក្នុងឆ្នាំទី១ នៃការអនុវត្តយុទ្ធសាស្រ្ត។ គោលបំណងសំខាន់ នៃការតាមដាន និងវាយតម្លៃគឺធ្វើការសម្រាំងជាបន្តបន្ទាប់ នៃការអនុវត្តយុទ្ធសាស្រ្ត។ យន្តការតាមដាន និងវាយតម្លៃគឺត្រូវធានាឲ្យបានផងដែរថា គោលដៅ ដែលបានអនុម័ត ត្រូវមានការចាត់វិធានការបានត្រឹមត្រូវទាន់ពេលវេលា ហើយគំនិតផ្តួចផ្តើម និងសកម្មភាព នៅតែស៊ីសង្វាក់គ្នានឹងគោលដៅទូទៅ ហើយគោលបំណងទូទៅទាំង ៤ នៅតែឆ្លើយតបទៅនឹងបញ្ហា និងអាទិភាពកំពុងកើតមាន។

នៅពេលការតាមដានបង្ហាញពីភាពជោគជ័យ និងបរាជ័យ ការវាយតម្លៃលម្អិតលើកត្តាចូលរួមចំណែក ឬ ដើមចម នៃបញ្ហា អាចផ្តល់នូវវិធីសាស្រ្ត ក្នុងការដោះស្រាយបញ្ហា។ យន្តការក្នុងការតាមដាន និងវាយតម្លៃនឹងត្រូវបានបង្កើតឡើងក្នុងរបៀបមួយដែលអាចសម្រេចបាន នូវគោលការណ៍មានតម្លាភាព និងគណនេយ្យភាព។

ការតាមដាន និងវាយតម្លៃត្រូវធ្វើឡើងតាម ២ ដំណាក់កាល:

- នៅទ្រង់ទ្រាយតូច គឺត្រូវមានផែនការតាមដាន និងវាយតម្លៃ ដែល បង្កើតឡើង ក្នុងសកម្មភាពនីមួយៗ
- នៅទ្រង់ទ្រាយធំគឺត្រូវមានយន្តការវាយតម្លៃរួម ដើម្បីធានាថាការអនុវត្តយុទ្ធសាស្រ្តរួម ដើរតាមគន្លងឆ្ពោះទៅរកការសម្រេចឲ្យបាន នូវគោលដៅរួម និងគោលបំណងទូទៅ

នៅទ្រង់ទ្រាយតូច សកម្មភាពផ្សេងៗមានបណ្តុំសូចនាករណ៍ និងគោលដៅជោគជ័យរបស់ខ្លួន ដោយពឹងផ្អែកលើគោលបំណង ដែលបានលើកឡើង។ នៅទ្រង់ទ្រាយធំ គឺធ្វើការប្រមូលផ្តុំជារួម នូវចំណុចវិនិច្ឆ័យត្រូវប្រើប្រាស់។ ចំណុចនេះ ប្រហែលជាត្រូវបញ្ចូលភាពសមស្រប/ភាពពាក់ព័ន្ធ (ស៊ីសង្វាក់គ្នានឹងទស្សនវិស័យអាស៊ានឆ្នាំ២០២០ និងផែនការរយៈពេលមធ្យមរបស់ខ្លួន និងកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលផ្សែងអ័ព្ទ (តម្រូវការតាមវិស័យ) ប្រសិទ្ធភាព (ការសម្រេចបាន នូវដំណើរការ និងលទ្ធផលតាមផែនការទទួលលទ្ធផល) ប្រសិទ្ធផល (កម្រិត នៃធនធានត្រូវការ ដើម្បីសម្រេចឲ្យបាន នូវលទ្ធផល និងគោលដៅ) ផលប៉ះពាល់ (ការចូលរួមចំណែកដល់ទស្សនវិស័យអាស៊ាន ២០២០ និងផែនការរយៈពេលមធ្យម និងកិច្ចព្រមព្រៀងអាស៊ាន ស្តីពី "ការបំពុលផ្សែងអ័ព្ទឆ្លងដែន" ការជៀសវាង នូវផលវិបាកជាអវិជ្ជមាន) និង និរន្តរភាព (ការរក្សានូវចំណេះដឹងទទួលបាន ធនធានកំពុងបន្តដែលសមស្រប សុឆន្ទៈនយោបាយ ដើម្បីរក្សានិរន្តរភាព នៃសន្ទុះ និងភាពបន្ត នៃលំហូរអត្ថប្រយោជន៍)។

ការសិក្សាស្ថានភាពមូលដ្ឋាន នៅពេលចាប់ផ្តើមអនុវត្តយុទ្ធសាស្រ្តគួរតែបង្កើតឡើង សម្រាប់ធ្វើជាចំណុចគោល ក្នុងការពិនិត្យឡើងវិញជាផ្លូវការ នៅទ្រង់ទ្រាយធំ។ ការប្រមូលទស្សនៈរបស់អ្នកពាក់ព័ន្ធពីវិស័យផ្សេងៗនឹងត្រូវធ្វើឡើង ដើម្បីទទួលបាននូវទស្សនមានគុណភាពតាមរយៈការវាយតម្លៃទ្រង់ទ្រាយតូច និងការវាយតម្លៃទ្រង់ទ្រាយធំ។

ការត្រួតពិនិត្យឡើងវិញជាផ្លូវការនៅទ្រង់ទ្រាយធំគួរធ្វើឡើង ដោយលេខាធិការអាស៊ានរៀងរាល់ ៥ឆ្នាំ។ អនុសាសន៍សម្រាប់ការពិនិត្យឡើងវិញ ឬធ្វើឲ្យមានបច្ចុប្បន្នភាពនៃយុទ្ធសាស្រ្ត ត្រូវបញ្ជូនមកស្ថាប័នអាស៊ាន ដែលពាក់ព័ន្ធ។ ការត្រួតពិនិត្យសារឡើងវិញចុងក្រោយនឹងត្រូវរៀបចំក្នុងឆ្នាំ ២០២០ និងរាយការណ៍ជូនស្ថាប័ន នៃរដ្ឋមន្ត្រីអាស៊ាន។